ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល



# ផែនការយុទ្ធសាស្ត្រជាតិ
# ស្តីពី
# ការការពារ និងគ្រប់គ្រងការលង់ទឹក

នាយកដ្ឋានការពារសុខភាព

២០២៥ - ២០៣០

# មាតិកា

មាតិកា ........ I
អារម្ភកថា ........ II
សេចក្តីថ្លែងអំណរគុណ ........ III
សទ្ទានុក្រម ........ V
សេចក្តីសង្ខេប ........ VII
១. សេចក្តីផ្តើម ........ ១
២. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង ........ ៣
២.១ ចក្ខុវិស័យ និងបេសកកម្ម ........ ៣
២.២ គោលបំណង និងលទ្ធផលរំពឹងទុក ........ ៣
២.២.១ គោលបំណង ........ ៣
២.២.២ លទ្ធផលរំពឹងទុក ........ ៣
៣. ការវិភាគបរិបទ និងកត្តាភាពងាយរងគ្រោះនៅនឹងការលង់ទឹកនៅកម្ពុជា ........ ៤
៣.១. ស្ថានភាព នៃការលង់ទឹកនៅកម្ពុជា ........ ៤
៣.២. បរិការណ៍នានា ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹកនៅកម្ពុជា ........ ៤
៣.៣. កត្តានានា នៃភាពងាយរងគ្រោះ និងគោលនយោបាយ ស្តីពីការលង់ទឹក ........ ៦
៣.៣.១. កត្តានានា នៃភាពងាយរងគ្រោះ ........ ៦
៣.៣.២. គោលនយោបាយ និងកម្មវិធីការងារអាទិភាព ........ ៨
៤. យុទ្ធសាស្ត្រ និងកម្មវិធីការងារអាទិភាព ........ ១០
៤.១ យុទ្ធសាស្ត្រអាទិភាពទាំង៤ សម្រាប់ការពារ និងគ្រប់គ្រងការលង់ទឹក ........ ១០
៤.២ កម្មវិធីការងារអាទិភាព និងសកម្មភាពចម្បងៗ ........ ១១
៥. យន្តការអនុវត្តផែនការយុទ្ធសាស្ត្រ ........ ២០
៥.១ តួអង្គសំខាន់ៗ និងអភិបាលកិច្ចលើការអនុវត្តន៍ ........ ២០
៥.២ ការរៀបចំផែនការការងារប្រចាំឆ្នាំ ........ ២០
៥.៣ ការកៀរគរធនធាន ការវិភាជន៍ធនធាន និងហិរញ្ញវត្ថុ ........ ២០
៦. ការពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍វឌ្ឍនភាព ........ ២១
៦.១ ការពិនិត្យតាមដាន និងរបាយការណ៍វឌ្ឍនភាព ........ ២១
៦.១.១ ការពិនិត្យតាមដាន (Monitoring) ........ ២១
៦.១.២ របាយការណ៍វឌ្ឍនភាព ........ ២២
៦.២ ការវាយតម្លៃតាមដំណាក់កាល និងការធ្វើបច្ចុប្បន្នភាពផែនការ ........ ២២

# អារម្ភកថា

ការលង់ទឹក គឺជាបញ្ហាសុខភាពសាធារណៈមួយ គួរឱ្យកត់សម្គាល់នៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក នឹងបានឆក់យកជីវិតមនុស្សជាង ៨៣ ៥០៨ នាក់ជារៀងរាល់ឆ្នាំ។ ប្រទេសកម្ពុជា ការលង់ទឹកគឺជាបញ្ហាសុខភាពសាធារណៈមួយដែលកំពុងប្រឈម ជាមួយនឹងអត្រា នៃការលង់ទឹកមានប្រមាណចំនួន ៧.៦ ដែលខ្ពស់ជាងអត្រាមធ្យមភាគសកល ៣.៨ និងក្នុងតំបន់ ៤.៣ ក្នុងចំណោមមនុស្ស ១០០ ០០០នាក់ យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោកឆ្នាំ២០២៤។ ការស្លាប់ភាគច្រើន គឺជាកុមារដែលមានអាយុក្រោម១៥ឆ្នាំ ដែលជាវ័យងាយរងគ្រោះ។

ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹកឆ្នាំ ២០២៥-២០៣០ ត្រូវបានផ្តួចផ្តើមរៀបចំដោយក្រសួងសុខាភិបាល មានការចូលរួមពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ យុទ្ធសាស្ត្រចម្បងៗ ដែលមានក្នុងផែនការយុទ្ធជាតិនេះ គឺផ្អែកតាមតម្រូវការជាក់ស្តែង ទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ ហានិភ័យ និងភាពងាយរងគ្រោះជាក់លាក់ សម្រាប់ដោះស្រាយបញ្ហាការលង់ទឹក ជាលក្ខណៈអន្តរវិស័យ។ ផែនការយុទ្ធសាស្ត្រជាតិនេះ មានគោលដៅស្របជាមួយនឹងក្របខ័ណ្ឌសកល និងតំបន់។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណដល់ក្រុមការងារ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមបង្កើតនូវផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក ដ៏មានសារសំខាន់។

ក្រសួងសុខាភិបាលសង្ឃឹមថា ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ នឹងយកផែនការយុទ្ធសាស្ត្រជាតិនេះទៅអនុវត្តន៍ ព្រមទាំងជួយជំរុញដោយចាត់ទុកកិច្ចការនេះ ជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងៗ ក្នុងការការពារអាយុជីវិតរបស់ប្រជាជន។

ថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

## សេចក្តីថ្លែងអំណរគុណ

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការការពារ និងគ្រប់គ្រងការលង់ទឹក ឆ្នាំ២០២៥-២០៣០ ត្រូវបានរៀបចំឡើងដោយនាយកដ្ឋានការពារសុខភាព នៃក្រសួងសុខាភិបាល និងមានការឧបត្ថម្ភគាំទ្រថវិកា និងបច្ចេកទេសពីអង្គការសុខភាពពិភពលោក (WHO) និងអង្គការចលនាដើម្បីសុខភាពនៅកម្ពុជា (CMH)។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម លោក លោកស្រី អ្នកនាង កញ្ញា អញ្ជើញមកពី ក្រសួង ស្ថាប័ននានា នាយកដ្ឋានពាក់ព័ន្ធ ក្រុមការងារបច្ចេកទេស មន្ទីរសុខាភិបាលខេត្ត ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ និងទីប្រឹក្សាបច្ចេកទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមចំណែកក្នុងការរៀបចំបង្កើតផែនការយុទ្ធសាស្ត្រជាតិនេះឡើង៖

### ក្រុមប្រឹក្សាបច្ចេកទេស នៃក្រសួងសុខាភិបាល

- ឯកឧត្តមវេជ្ជបណ្ឌិត **សាន់ សាប់អឺ** រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល
- ឯកឧត្តមវេជ្ជបណ្ឌិត **ពាស់ មុស្លឹម** រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល
- ឯកឧត្តមវេជ្ជបណ្ឌិត **ហុក គឹមចេង** អគ្គនាយកបច្ចេកទេសសុខាភិបាល

### ក្រុមការងារបច្ចេកទេស និងក្រុមជំនាញការ នៃអង្គការដៃគូអភិវឌ្ឍនានា

- ឯកឧត្តមវេជ្ជបណ្ឌិត **សុទ្ធ គឹមកុលមុនី** អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- លោកវេជ្ជបណ្ឌិត **កុល ហៀវ** ប្រធាននាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល
- លោកស្រីវេជ្ជបណ្ឌិត **ឡាក់ មួយស៊ាង** អនុប្រធាននាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល
- លោកទន្តបណ្ឌិត **ហ៊ា ស៊ីផាន** អនុប្រធាននាយកដ្ឋានធនធានមនុស្ស ក្រសួងសុខាភិបាល
- លោក **គាំ ស៊ីន្ទួន** អនុប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងសុខាភិបាល
- លោកវេជ្ជបណ្ឌិត **ឡាក់ ឡេង** អនុប្រធានមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព
- លោកឧត្តមសេនីយត្រី **ឯក ចាន់ប៉ូលី** អនុប្រធាននាយកដ្ឋានការពារព្រំដែនទឹក ក្រសួងមហាផ្ទៃ
- លោក **កើត ពុទ្ធវណ្ណ** អនុប្រធាននាយកដ្ឋាន ក្រសួងធនធានទឹក និងឧតុនិយម
- លោក **អៀន សុខគី** ប្រធានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន
- លោក **តុង សេង** ប្រធានការិយាល័យ ក្រសួងធនធានទឹក និងឧតុនិយម
- លោកវរសេនីយ៍ឯក **សុខ រស្មី** ប្រធានការិយាល័យ ក្រសួងការពារជាតិ
- លោក **លន់ ឡាក់** ប្រធានការិយាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន
- លោកឱសថការី **ផុល ពន្លឺ** អនុប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តត្បូងឃ្មុំ
- លោកវេជ្ជបណ្ឌិត **តឹក សុភាព** អនុប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តពោធិ៍សាត់
- លោកគ្រូពេទ្យ **លាង ឌីណា** អនុប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តក្រចេះ
- លោកស្រី **ឆាន់ ចន្ទសោភ័ណ** អនុប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបន្ទាយមានជ័យ
- លោក **អុប ពុទ្ធា** ប្រធានការិយាល័យសង្គ្រោះបឋម កាកបាទក្រហមកម្ពុជា
- លោកវេជ្ជបណ្ឌិត **ហ៊ង ឡៅប៉ូ** អនុប្រធានការិយាល័យ ក្រសួងសុខាភិបាល
- លោកស្រី **ម៉ៅ តាន់ណារី** អនុប្រធានការិយាល័យ ក្រសួងអប់រំ យុវជន និងកីឡា
- លោក **ជិន អាត** អនុប្រធានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន

- លោក **តូង រដ្ឋា** អនុប្រធានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន
- លោកវេជ្ជបណ្ឌិត **អ៊ឹម សុភា** អនុប្រធានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន
- លោក **សេង ច័ន្ទវិសាល** អនុប្រធានការិយាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន
- លោកវេជ្ជបណ្ឌិត **ព្រហ្ម ប៉ូលីម** អនុប្រធានការិយាល័យ ក្រសួងអភិវឌ្ឍជនបទ
- លោកគ្រូពេទ្យ **ឈិម ថា** ប្រ.ការិ.បង្ការជំងឺ និងគ្រប់គ្រងជំងឺ មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តពោធិ៍សាត់
- លោកស្រី **ញឹម គឹមធី** ប្រ.ផ្នែកសុខភាពបរិស្ថាននិងគ្រោះមហន្តរាយមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបាត់ដំបង
- លោក **នៅ មូលីកា** មន្ត្រី នាយកដ្ឋានការពារសុខភាព
- លោក **អ៊ឹម ពិសិដ្ឋ** មន្ត្រី នាយកដ្ឋានការពារសុខភាព
- លោកវេជ្ជបណ្ឌិត **ម៉ូវ ឆ័យយុត្តិ** មន្ត្រី នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
- កញ្ញា **សុខ ង៉ូវលីលី** មន្ត្រី វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- លោកស្រី **ឡុង គឹមណា** មន្ត្រី នាយកដ្ឋានសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា
- លោកវេជ្ជបណ្ឌិត **ប៊ិ ភារីន** មន្ត្រី មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តកំពង់ចាម
- លោកវេជ្ជបណ្ឌិត **ឃិល ដារ៉ារុជ** មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក (WHO)
- លោកវេជ្ជបណ្ឌិត **មុំ គង់** នាយកប្រតិបត្តិអង្គការចលនាដើម្បីសុខភាពកម្ពុជា (CMH)
- លោក **ហ៊ាង ផាត** អ្នកជំនាញគោលនយោបាយសង្គមរបស់អង្គការយូនីសេហ្វ (UNICEF)
- លោកស្រី **សយ សូលីដា** ទីប្រឹក្សា អង្គការយូនីសេហ្វ (UNICEF)
- លោក **ជ័យ រតនា** នាយកប្រតិបត្តិអង្គការហេបកូដ កម្ពុជា
- លោកស្រី **តិ សារ៉ាត់** នាយិកាប្រតិបត្តិ អង្គការហែលទឹក កម្ពុជា

**ទីប្រឹក្សាបច្ចេកទេស៖**

- លោក **សេង សំបាន** ប្រធានក្រុមទីប្រឹក្សាបច្ចេកទេសឯករាជ្យ
- លោក **ឌុច សំអាង** ទីប្រឹក្សាជំនួយបច្ចេកទេសឯករាជ្យ

# សទ្ទានុក្រម

| | |
|---|---|
| ការលង់ទឹក<br>Drowning | ការលង់ទឹក គឺជាការស្ទះផ្លូវដង្ហើមដោយសារការជ្រាបចូល នៃទឹកទៅក្នុងផ្លូវដង្ហើម រហូតដល់ថង់សួត ដែលបណ្តាលមកពីជនរងគ្រោះ (ពិសេសមុខ) ត្រូវបានជ្រមុជចូលទៅក្នុងទឹក។ |
| ការសង្គ្រោះបឋម[1]<br>First Aid | - ការសង្គ្រោះបឋម គឺជាការសង្គ្រោះបណ្តោះអាសន្ន និងបន្ទាន់ដល់ជនរងគ្រោះ ឬជនដែលមានជំងឺគំហុកភ្លាមៗ តាមរយៈការប្រើប្រាស់សម្ភារបរិក្ខា ដែលមាននៅក្នុងពេល ឬមុនពេលមានជំនួយវេជ្ជសាស្ត្រមកដល់<br>- សេចក្តីត្រូវការនូវការថែទាំ នៅក្នុងគ្រាមានអាសន្ន មានចាប់តាំងពីកន្លែងដែលមានឧប្បត្តិហេតុបន្ទាន់ ទោះបីជាគ្រោះថ្នាក់បុកប៉ះ ឬករណីបន្ទាន់វេជ្ជសាស្ត្រ។ វាបន្តតាំងពីការចូលរួមជួយពីសំណាក់សាធារណៈជននៅចំណុចកើតហេតុ រហូតដល់ចុងបញ្ចប់ គឺស្តារលទ្ធភាពឡើងវិញ នៅក្រោយការថែទាំ។ |
| ភាពងាយរងគ្រោះ[2]<br>Vulnerability | ភាពងាយរងគ្រោះ គឺសំដៅដល់លក្ខខណ្ឌដែលកំណត់ដោយកត្តារូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន ឬជាដំណើរការ ដែលបង្កើតនូវភាពចុះខ្សោយរបស់សហគមន៍ ទៅនឹងផលប៉ះពាល់ នៃមុខសញ្ញាគ្រោះថ្នាក់។ |
| សុវត្ថិភាពទឹក[3]<br>Water Safety | សុវត្ថិភាពទឹក គឺសំដៅដល់និតិវិធី វិធានការបង្ការ និងគោលនយោបាយនានាពាក់ព័ន្ធ និងសុវត្ថិភាពនៅក្នុងទឹក លើទឹក និងនៅជុំវិញបរិវេណមានទឹក ដែលកន្លែងទាំងនេះ អាចមានហានិភ័យជារបួស ឬលង់ទឹក។ ការអនុវត្តសុវត្ថិភាពទឹកនៅក្នុងវិស័យនានា ជាច្រើនដូចជា កីឡា ឬសកម្មភាពកំសាន្តនានាផងដែរ។ |
| ការរុករក និងសង្គ្រោះ[4]<br>Search and Rescue | ការរុករក និងសង្គ្រោះ គឺជាការស្វែងរក ឬរុករក ដើម្បីផ្តល់ជំនួយដល់អ្នកដែលកំពុងជួបបញ្ហា ឬគ្រោះថ្នាក់ជាក់ស្តែង។ |
| ការប៉ាន់ប្រមាណហានិភ័យ[5]<br>Risk Assessment | ការប៉ាន់ប្រមាណហានិភ័យ គឺសំដៅដល់វិធីសាស្ត្រ ដើម្បីកំណត់លក្ខណៈ និងកម្រិតនៃហានិភ័យ ដោយធ្វើការវិភាគមុខសញ្ញាគ្រោះថ្នាក់ ដែលអាចកើតមាន និងវាយតម្លៃលើលក្ខខណ្ឌដែលមានស្រាប់ នៃភាពងាយរងគ្រោះ ដែលកត្តាទាំងពីរអាចបង្កមហន្តរាយដល់មនុស្ស ទ្រព្យសម្បត្តិ សេវាកម្ម ជីវភាពរស់នៅ និងបរិស្ថាន។ |

[1] ចលនាកាកបាទក្រហមនិងអឌ្ឍច័ន្ទក្រហម

[2] ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

[3] Wikipedia

[4] Wikipedia

[5] ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

| | |
|---|---|
| ការវិភាគតួអង្គប្រតិបត្តិ[6]<br>Stakeholder analysis | ការវិភាគតួអង្គប្រតិបត្តិ គឺជាដំណើរការ នៃការកំណត់ និងសិក្សាពីចំណាប់អារម្មណ៍ អំពីឥទ្ធិពល និងផលជះ នៃភាគីតួអង្គនានាទៅលើគម្រោង ឬការសម្រេចចិត្តលើកិច្ចការណាមួយ។ |
| ការវិភាគគោលនយោបាយ<br>Policy Analysis | ការវិភាគគោលនយោបាយ គឺសំដៅដល់ដំណើរនៃការវាយតម្លៃ និងប្រៀបធៀបជម្រើសនានា ដើម្បីដោះស្រាយបញ្ហាសាធារណៈផ្សេងៗ ហើយការជ្រើសរើសយកជម្រើសសមស្របណាមួយ។ វាជាផ្នែកចាំបាច់មួយ នៃដំណើរការរៀបចំគោលនយោបាយ។ ការវិភាគគោលនយោបាយ ដើម្បីបង្កើតគោលនយោបាយថ្មី ឬកែលម្អគោលនយោបាយដែលមានស្រាប់។ |
| ផែនការត្រៀមបម្រុង[7]<br>Contingency Plan | ផែនការត្រៀមបម្រុង គឺសំដៅដល់ការគ្រប់គ្រងដំណើរការ ធ្វើការវិភាគលើព្រឹត្តិការណ៍កើតឡើង ឬស្ថានភាពអាចកើតឡើង នឹងអាចគំរាមកំហែងសង្គម ឬបរិស្ថាន និងការរៀបចំទុកជាក់ ដើម្បីចាត់ចែងពេលខាងមុខប្រកបដោយសមត្ថភាព និងទាន់ពេលវេលាទៅនឹងព្រឹត្តិការណ៍ និងស្ថានភាពទាំងនោះ។ |
| ការប្រកាសឱ្យដឹងមុន[8]<br>Early Warning | ការប្រកាសឱ្យដឹងមុន គឺសំដៅដល់សមត្ថភាព ដែលតម្រូវឱ្យមានការបង្កើតសម្រាប់ប្រមូល និងផ្សព្វផ្សាយទាន់ពេលវេលា និងប្រកាសព័ត៌មាន ដែលមានន័យគ្រប់គ្រាន់ទៅដល់ក្រុមមនុស្ស សហគមន៍ និងស្ថាប័ន ដែលគំរាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់ ដើម្បីត្រៀមធ្វើឱ្យសមស្រប និងទាន់ពេលវេលាពីការកាត់បន្ថយលទ្ធភាព នៃការអន្តរាយ ឬបាត់បង់។ |
| ឆ្មាំជីវិត ឬឆ្មាំការពារ[9] | ឆ្មាំជីវិត ឬឆ្មាំការពារ គឺជាអ្នកសង្គ្រោះដែលតាមឃ្លាំមើលសុវត្ថិភាព ព្រមទាំងធ្វើការសង្គ្រោះ អ្នកហែលទឹក អ្នកបណ្តែតខ្លួនលើផ្ទៃទឹក និងអ្នកលេងទឹកផ្សេងទៀតដូចជា នៅក្នុងអាងហែលទឹក សួនលំហែទឹក ឆ្នេរ បឹង និងទន្លេជាដើម។ |

[6] Project Management Institute
[7] ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
[8] ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
[9] Wikipedia

# សេចក្តីសង្ខេប

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលសំបូរដោយប្រភពទឹកដូចជា ទន្លេ សមុទ្រ ស្ទឹង បឹងបួរនានា ក្នុងនោះ ទន្លេមេគង្គ និងបឹងទន្លេសាបជាប្រភពទឹកចម្បងពីរ ដែលបម្រើជាប្រយោជន៍យ៉ាងច្រើនលើសលុបដល់ជីវភាព និងសេដ្ឋកិច្ចជាតិ ដោយវាជាផ្លូវទឹកសម្រាប់ដឹកជញ្ជូនផងដែរ។ ក្រៅពីនេះក៏នៅមានប្រភពទឹកជាច្រើនផ្សេងៗទៀត ដែលហូរកាត់ខ្វាត់ខ្វែងលើផ្ទៃប្រទេសមិនថានៅតំបន់ទំនាបកណ្តាល នៅជួរភ្នំ ខ្ពង់រាប និងតាមតំបន់ឆ្នេរ។ ក្រៅពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច គេក៏សង្កេតឃើញថាជាប្រភពហានិភ័យឈានដល់ការបាត់បង់ជីវិតប្រជាជនផងដែរ ដោយសារការលង់ទឹក។ បើយោងតាមទិន្នន័យប៉ាន់ស្មានសុខភាពសកលដែលបានចេញផ្សាយក្នុងឆ្នាំ២០២១ ប្រទេសកម្ពុជាមានអត្រាមរណភាព នៃការលង់ទឹកថ្នាក់ជាតិប្រមាណ ៧,៦នាក់ ក្នុងចំណោមមនុស្ស១០ម៉ឺននាក់ ដែលខ្ពស់ជាងមធ្យមភាគក្នុងតំបន់ដែលមាន ៤,៣នាក់ និងមធ្យមភាគសកលមានតែ ៣,៨[10]នាក់ ក្នុងចំណោមមនុស្ស១០ម៉ឺននាក់។

បញ្ហាលង់ទឹកត្រូវបានចាត់ទុកជាបញ្ហាសុខភាពសាធារណៈ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងចូលរួមដោះស្រាយជាបន្ទាន់។ ទន្ទឹមនឹងអាទិភាពបែបនេះ គេសង្កេតឃើញជារួមថាការដោះស្រាយបញ្ហាលង់ទឹក តាមរយៈវិធានការការពារ និងគ្រប់គ្រងការលង់ទឹកគឺនៅមានកម្រិតនៅឡើយ បើធៀបនឹងវិស័យការងារផ្សេងៗទៀតនៅព្រះរាជាណាចក្រកម្ពុជា។ នេះជាលើកទីមួយ សម្រាប់ព្រះរាជាណាចក្រកម្ពុជាដែលបានរៀបចំចងក្រងផែនការយុទ្ធសាស្រ្តជាតិនេះឡើង។

ផែនការយុទ្ធសាស្រ្តជាតិសម្រាប់ការការពារ និងគ្រប់គ្រងការលង់ទឹក ត្រូវបានរៀបចំឡើងដោយក្រសួងសុខាភិបាល ដោយមានកិច្ចសហការទាំងបច្ចេកទេស និងហិរញ្ញវត្ថុជាមួយអង្គការសុខភាពពិភពលោក និងដៃគូអភិវឌ្ឍមួយចំនួនទៀត ក្នុងគោលបំណងដាក់ចេញ នូវទិសដៅយុទ្ធសាស្រ្តជាអាទិភាពចម្បងៗនានា ឈានទៅការកាត់បន្ថយករណីលង់ទឹក និងការបាត់បង់ជីវិតដោយការលង់ទឹក តាមរយៈការការពារ និងគ្រប់គ្រងការលង់ទឹក។

គួរកត់សម្គាល់ថាទោះជាផែនការយុទ្ធសាស្រ្តនេះ ត្រូវបានផ្តួចផ្តើមរៀបចំដោយក្រសួងសុខាភិបាល ត្រូវបានប្រើជាលក្ខណៈក្របខ័ណ្ឌជាតិសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលគ្រប់ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងផ្នែកឯកជន អាចគាំទ្រ និងទាញយកយុទ្ធសាស្រ្តអាទិភាពនានាដែលពាក់ព័ន្ធនឹងភារកិច្ចស្នូលរបស់ស្ថាប័នខ្លួនយកទៅអនុវត្តន៍តាមជំនាញរៀងៗខ្លួន។

ឆ្លើយតបនឹងគោលបំណងដាក់លាក់ខាងលើ ផែនការយុទ្ធសាស្រ្តជាតិ ត្រូវបានដាក់ចេញនូវយុទ្ធសាស្រ្តចម្បង និងអាទិភាពចំនួន៤ ដើម្បីការការពារ និងគ្រប់គ្រងការលង់ទឹកដែលមានដូចខាងក្រោម៖

- **យុទ្ធសាស្រ្តទី១៖** អភិវឌ្ឍន៍ និងលើកកម្ពស់ការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយជាក់លាក់នៃការការពារ និងគ្រប់គ្រងការលង់ទឹក។
- **យុទ្ធសាស្រ្តទី២៖** លើកកម្ពស់ការផ្តល់សេវាសុខភាព ការអប់រំផ្សព្វផ្សាយ ការយល់ដឹង ការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថងាយរងគ្រោះនានា ដើម្បីការការពារ និងគ្រប់គ្រងការលង់ទឹក។

[10] Global Health estimation 2021

- <u>យុទ្ធសាស្ត្រទី៣៖</u> លើកកម្ពស់ការគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យពីការលង់ទឹកជាមូលដ្ឋានសម្រាប់ធ្វើផែនការ និងចាត់វិធានការនានាឱ្យបានសមស្របតាមតម្រូវការជាក់ស្តែង នៃភាពងាយរងគ្រោះដោយការលង់ទឹក។
- <u>យុទ្ធសាស្ត្រទី៤៖</u> ពង្រឹងយន្តការ និងសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តន៍ ការងារការការពារ និងគ្រប់គ្រង់ការលង់ទឹក។

បន្ថែមពីលើទិសដៅស្នូលទាំង៤ខាងលើ ផែនការយុទ្ធសាស្ត្រជាតិនេះ ក៏បានផ្តោតការយកចិត្តទុកដាក់ដល់កត្តាគន្លឹះផ្សេងៗមួយចំនួន ដែលជាកាតាលីករជួយជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រឱ្យបានលទ្ធផល និងប្រកបដោយប្រសិទ្ធភាព និងបរិយាប័ន្ន ដែលស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះមានដូចជា៖

- តម្រូវការឱ្យមានផែនការជាក់លាក់ប្រចាំឆ្នាំ ដើម្បីប្រែក្លាយយុទ្ធសាស្ត្រអាទិភាព ដែលបានដាក់ចេញទាំង៤ ឱ្យទៅជាសកម្មភាពការងារជាក់លាក់។ ការងារនេះចាំបាច់ឱ្យមានទម្រង់ ជាអន្តរស្ថាប័ន ហើយគួរបញ្ជ្រាបទៅក្នុងយន្តការ ធ្វើផែនការរបស់ក្រសួងសុខាភិបាលផងដែរ។ មុននឹងរៀបចំផែនការប្រចាំឆ្នាំ ជាការចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សាទិន្នន័យដើមគ្រា ជាមុនសិនសម្រាប់ជាមូលដ្ឋានដាក់ចេញនូវយុទ្ធសាស្ត្រអនុវត្តសមស្រប និងសម្រាប់បង្កើតសូចនាករទាំងគុណភាព និងបរិមាណដែលសមស្រប។
- ការវិភាជន៍ និងកៀរគរធនធានសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ។ ដើម្បីឱ្យកិច្ចការនេះបានដំណើរការ និងមានរូបភាពគត់មត់ចាំបាច់ត្រូវមានរៀបចំជាផែនការ និងក្របខ័ណ្ឌការងារជាក់លាក់មួយស្តីពីការកៀរគរ និងវិភាជន៍ធនធានសម្រាប់អនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ។
- តម្រូវការឱ្យមានយន្តការការងារជាក់លាក់សម្រាប់ការការពារ និងគ្រប់គ្រងការលង់ទឹកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ក្នុងកម្រិតដៃគូជាយុទ្ធសាស្ត្រ និងដៃគូអនុវត្ត។ ក្នុងកិច្ចការនេះ ជាការចាំបាច់ត្រូវធ្វើការវិភាគ តួអង្គ និងមុខងារស្ថាប័នដែលជាតួអង្គជាក់លាក់សម្រាប់ជាមូលដ្ឋានគាំទ្រដល់ការរៀបចំផែនការឱ្យមានការចូលរួមរបស់តួអង្គទាំងនោះ (Stakeholder engagement plan)។
- ការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ។ ជាការចាំបាច់ត្រូវបញ្ជ្រាបការងារពិនិត្យតាមដាន និងវាយតម្លៃទៅក្នុងយន្តការរៀបចំផែនការពិនិត្យតាមដាន វាយតម្លៃ និងការងាររបាយការណ៍របស់ក្រសួងសុខាភិបាល។

ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹកនេះ កំណត់ផែនការសកម្មភាពពីឆ្នាំ២០២៥ ដល់ឆ្នាំ២០៣០។ ដោយសារនេះ ជាយុទ្ធសាស្ត្រជាតិទប់ស្កាត់ការលង់ទឹកលើកដំបូងរបស់កម្ពុជា ចាំបាច់ឱ្យមានការវាយតម្លៃពាក់កណ្តាលគ្រានៅចុងឆ្នាំ២០២៧ ដើម្បីជួយតម្រង់ទិសការងារនៅដំណាក់កាលបន្ទាប់ពីឆ្នាំ២០២៨ ដល់២០៣០។ ជាងនេះទៅទៀត ដោយសារផែនការមេរបស់ក្រសួងសុខាភិបាលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០៣២ ដូច្នេះ ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹកចាំបាច់ត្រូវតែបញ្ចប់ជាស្ថាពរជាមុនសិន ដើម្បីបញ្ចប់ការវាយតម្លៃបញ្ចប់ចុងគ្រា និងដាក់ចេញនូវអនុសាសន៍ និងទិសដៅនានា ដើម្បីបញ្ជ្រាបចូលទៅក្នុងដំណាក់កាលបន្ទាប់ នៃផែនការមេរបស់ក្រសួងសុខាភិបាល។

## ១. សេចក្តីផ្តើម

មនុស្សជាង ៨៣,៥០៨ នាក់បានលង់ទឹកជារៀងរាល់ឆ្នាំ[11] នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដោយជាមធ្យមមាន១នាក់ ស្លាប់រៀងរាល់ប្រាំមួយនាទីម្តង[12]។ អត្រាមរណៈ នៃការលង់ទឹកគឺខ្ពស់ ជាពិសេសនៅក្នុងតំបន់នេះ ដែលបង្ហាញពីបញ្ហាប្រឈមផ្នែកសុខភាពសាធារណៈយ៉ាងសំខាន់ ជាពិសេស សម្រាប់ក្រុមដែលងាយរងគ្រោះ។ គួរកត់សម្គាល់ថា ៣១% នៃការស្លាប់ដោយសារការលង់ទឹកពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៥ឆ្នាំ ហើយអត្រាខ្ពស់បំផុត គឺកុមារដែលមានអាយុ ១ដល់ ៤ឆ្នាំ[13]។ ទោះបីជាមានការយល់ដឹងជាច្រើនទសវត្សរ៍មកក៏ដោយ អំពីបញ្ហាលង់ទឹកនេះ ប៉ុន្តែក្នុងរយៈពេល ៤០ឆ្នាំចុងក្រោយ មានការរីកចម្រើនតិចតួចក្នុងការកាត់បន្ថយការស្លាប់ដោយលង់ទឹកនៅក្នុងតំបន់ អាស៊ីប៉ាស៊ីហ្វិក ដែលជាតម្រូវការសំខាន់សម្រាប់គោលដៅអន្តរាគមន៍[14]។

នៅព្រះរាជាណាចក្រកម្ពុជា ការលង់ទឹកគឺបណ្តាលឱ្យបាត់បង់ជីវិតជាបន្តបន្ទាប់ ដែលនេះជាកត្តាមួយដ៏សំខាន់ក្នុងចំណោមមូលហេតុផ្សេងៗ នៃការស្លាប់។ យោងតាមទិន្នន័យប៉ាន់ស្មានរបស់អង្គការសុខភាពពិភពលោក បានចេញផ្សាយក្នុងឆ្នាំ២០២៤ ប្រទេសកម្ពុជាមានអត្រាមរណៈ ដោយការលង់ទឹកប្រមាណ ៧.៦នាក់ ក្នុងចំណោមមនុស្ស ១០០,០០០នាក់ ដែលខ្ពស់ជាងអត្រាក្នុងតំបន់ ដែលមាន ៤.៣ នាក់ និង អត្រាសកលដែលមានតែ ៣.៨[15]នាក់។

ការលង់ទឹកមិនត្រឹមតែប៉ះពាល់ដល់សុខភាពសាធារណៈប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់យ៉ាងសំខាន់ដល់ធនធានមនុស្ស និងសេដ្ឋកិច្ច។ នៅទូទាំងពិភពលោក ការប៉ាន់ប្រមាណការបាត់បង់ឱកាសសម្រាប់សង្គមពីការលង់ទឹកមានចំនួន ១៤៦,៩៣ពាន់លានដុល្លារ ក្នុងឆ្នាំ២០១៩ ដែលការបាត់បង់នេះ អាចការពារបាន[16]។

| ប្រទេស | អត្រាមរណៈក្នុងចំណោម១០០,០០០ នាក់ | សរុប | បុរស | ស្ត្រី |
|---|---|---|---|---|
| ថៃ | | ៨.៨ | ១៤.៨ | ២.៩ |
| វៀតណាម | | ៨.២ | ១១.៨ | ៤.៤ |
| កម្ពុជា | | ៧.៨ | ១១.៨ | ៣.៩ |
| ឡាវ | | ៧.៤ | ៩.៨ | ៤.៩ |
| បង់ក្លាដេស | | ៥.៥ | ៦.១ | ៥.០ |
| ភូមា | | ៥.៣ | ៨.០ | ២.៦ |
| ចិន | | ៤.០ | ៥.៣ | ២.៥ |
| ម៉ាឡេស៊ី | | ២.៨ | ៤.៥ | ១.១ |
| សិង្ហបុរី | | ០.៣ | ០.៥ | ០.១ |

[11] Global Health Estimates 2021: Estimated drowning deaths in the Western Pacific Region
[12] WHO Drowning Prevention Factsheet 2019
[13] - ibid -
[14] - ibid -
[15] Global Health estimation 2021
[16] https://www.worldlifeexpectancy.com/cambodia-drownings

ការការពារការលង់ទឹកបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញការប្ដេជ្ញាចិត្តជាសកល រួមទាំងគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ នៃអង្គការសហប្រជាជាតិឆ្នាំ២០៣០ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (ការពង្រឹងភាពធន់របស់សហគមន៍ចំពោះការប្រែប្រួលអាកាសធាតុ) ក្របខ័ណ្ឌការងារសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ ២០១៥-២០៣០ និងការធានារ៉ាប់រងសុខភាពសកល។ ជាពិសេស អន្តរាគមន៍ការពារការលង់ទឹកអាចរួមចំណែកដល់គោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើនរួមមានគោលដៅ (១).គ្មានភាពក្រីក្រ (២).សុខភាពល្អ និងសុខុមាលភាព (៣).ការអប់រំប្រកបដោយគុណភាព (៤).សមភាពយេនឌ័រ (៥).ទឹកស្អាតជ និងអនាម័យ (៦).ការងារសមរម្យនិងកំណើនសេដ្ឋកិច្ច (៧).កាត់បន្ថយវិសមភាព (៨). ចីរភាពទីក្រុងនិងសហគមន៍ និង(៩).ភាពធន់នឹងអាកាសធាតុ។ តាមរយៈការដោះស្រាយគោលដៅទាំងនេះ កិច្ចខិតខំប្រឹងប្រែងការពារការលង់ទឹក បានគាំទ្រដល់គោលដៅបឋមភាពកុមារ ដែលទាក់ទងនឹងការស្លាប់ ការអប់រំ ការចាក់ថ្នាំបង្ការ និងអាហារូបត្ថម្ភបម្រើជាវិធានការនវានុវត្តន៍ សម្រាប់ការរស់រានមានជីវិតរបស់កុមារ និងការការពារការវិនិយោគលើកុមារ និងការអភិវឌ្ឍមនុស្សវ័យជំទង់ ជាពិសេសនៅក្នុងប្រទេសដែលមានអត្រា នៃការស្លាប់ដោយសារការលង់ទឹកខ្ពស់។

នៅព្រះរាជាណាចក្រកម្ពុជា ការលង់ទឹកគឺមានការកើតឡើងជាបន្តបន្ទាប់តាមរូបភាព និងប្រភេទផ្សេងៗគ្នា ទាំងនៅរដូវវស្សា (ទឹកជំនន់) និងរដូវប្រាំង។ ការលង់ទឹកត្រូវបានចាត់ទុកជាបញ្ហាសុខភាពសាធារណៈ ហើយក្រសួងសុខាភិបាល តាមរយៈនាយកដ្ឋានការពារសុខភាព បានសហការជាមួយក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដូចជាអង្គការសុខភាពពិភពលោកជាដើម ដែលបានផ្ដួចផ្ដើមដោះស្រាយបញ្ហានេះ។




Cambodia Death by flood (ទិន្នន័យស្លាប់ដោយទឹកជំនន់)

*Source (ប្រភព): https://camdi.ncdm.gov.kh/DesInventar/profiletab.jsp*

ផែនការយុទ្ធសាស្ត្រជាតិនេះ រៀបចំឡើងសំដៅកាត់បន្ថយការលង់ទឹកនៅក្នុងប្រទេស តាមរយៈកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលគ្រប់ជ្រុងជ្រោយ និងប្រកបដោយនិរន្តរភាព។ ផែនការយុទ្ធសាស្ត្រជាតិនេះជាមគ្គុទ្ទេសក៍ សម្រាប់សកម្មភាពជាតិ ដែលធានាបន្សុីជាមួយនឹងអាទិភាពសុខភាព និងសុវត្ថិភាពរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមចំណែកសម្រេចបាន៖

- ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ ២០២៤-២០២៨ ( NAP-DRR 2024 - 2028 )
- យុទ្ធសាស្ត្រការពារការលង់ទឹកសកលរបស់អង្គការសុខភាពពិភពលោក
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ( Sustainable Development Goals - SDGs )។

ផែនការយុទ្ធសាស្ត្រជាតិនេះ សម្រាប់ការការពារ និងគ្រប់គ្រងការលង់ទឹក មានវិសាលភាពក្នុងទម្រង់ជាអន្តរវិស័យ និងពហុវិស័យ។

# ២. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង

## ២.១. ចក្ខុវិស័យ និងបេសកកម្ម

**ចក្ខុវិស័យ ៖** ការលង់ទឹកលែងជាបុព្វហេតុ នៃការស្លាប់ដែលគេអាចការពារបាននៅកម្ពុជា។

**បេសកកម្ម៖** ការពារ និងកាត់បន្ថយការលង់ទឹកនៅកម្ពុជា តាមរយៈការលើកកម្ពស់ការអប់រំ ផ្សព្វផ្សាយ ពង្រឹងសមត្ថភាព គោលនយោបាយ កម្មវិធីផ្សេងៗ និងការឆ្លើយតបទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព។

## ២.២. គោលបំណង និងលទ្ធផលរំពឹងទុក

### ២.២.១. គោលបំណង

ដើម្បីការពារពីការលង់ទឹក កាត់បន្ថយការបាត់បង់អាយុជីវិត របួសស្នាម និងលើកកម្ពស់សុខមាលភាព សហគមន៍នៅកម្ពុជា តាមរយៈសកម្មភាពការការពារ និងគ្រប់គ្រងការលង់ទឹកឱ្យកាន់តែមានប្រសិទ្ធភាព។

### ២.២.២. លទ្ធផលរំពឹងទុក

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ នឹងឈានទៅសម្រេចបានលទ្ធផលរំពឹងទុកដូចខាងក្រោម៖

១-អត្រា នៃការស្លាប់ដោយសារការលង់ទឹក ក្នុងចំណោមក្រុមគោលដៅជាក់លាក់មានការថយចុះនៅកម្ពុជា

២-ក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ មានផែនការជាក់លាក់ជាងមុន និងបង្កើនការចូលរួមកិច្ចការពារ និងគ្រប់គ្រងការលង់ទឹក តាមសមត្ថកិច្ចរៀងៗខ្លួន ដោយមានការចង់ក្រងជាឯកសារគោលការណ៍ណែនាំ និងការបណ្តុះបណ្តាលនានា។

៣- ចំណេះដឹង ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹកមានការកើនឡើង ដោយរួមទាំងការយល់ដឹងពីកត្តានានា នៃភាពងាយរងគ្រោះទៅនឹងការលង់ទឹកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងសហគមន៍ងាយរងគ្រោះផងដែរ។
៤- កត្តា នៃភាពងាយរងគ្រោះនានា និងហានិភ័យ នៃការលង់ទឹកស្លាប់ ត្រូវបានសិក្សា និងកំណត់បានជាក់លាក់ ដើម្បីជាមូលដ្ឋានសម្រាប់ដាក់ចេញផែនការឆ្លើយតប និងយុទ្ធនាការសមស្របនានា។
៥- មានការផ្លាស់ប្តូរអាកប្បកិរិយា (Behavior) និងឥរិយាបថ (Attitude) ព្រមទាំងសកម្មភាពជាក់លាក់ឆ្លើយតបនឹងប្រភេទនានា នៃភាពងាយរងគ្រោះ និងហានិភ័យ ក្នុងចំណោមក្រុមគោលដៅ ដើម្បីការពារ និងគ្រប់គ្រងការលង់ទឹក។
៦- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹកត្រូវបានរៀបចំអនុម័តដាក់ឱ្យប្រើប្រាស់ និងមានយន្តការតាមដានដាក់លាក់លើវឌ្ឍនភាព។

# ៣. ការវិភាគបរិបទ និងកត្តាភាពងាយរងគ្រោះទៅនឹងការលង់ទឹកនៅកម្ពុជា

## ៣.១. ស្ថានភាព នៃការលង់ទឹកនៅកម្ពុជា

ប្រទេសកម្ពុជាកំពុងប្រឈមនឹងហានិភ័យ នៃការលង់ទឹកគួរឱ្យកត់សម្គាល់ ដោយអត្រាមរណៈនៃអ្នកលង់ទឹកមានចំនួន ១,២៨៤នាក់ ស្ថិតក្នុងកម្រិត ៧.៦នាក់ក្នុងចំណោមមនុស្ស ១០០,០០០ នាក់ ផ្អែកតាមទិន្នន័យប៉ាន់ស្មានរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០២១។ អត្រានេះ គឺខ្ពស់ជាងមធ្យមភាគក្នុងតំបន់ ៤.៣ នាក់ និងមធ្យមភាគសកល ៣.៨ នាក់ ក្នុងមនុស្ស ១០០,០០០ នាក់។ តាមរយៈទិន្នន័យនេះ បានបង្ហាញឱ្យឃើញថា អត្រាមរណៈដោយសារការលង់ទឹក មានច្រើនលើសលប់ដែលតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាជាបន្ទាន់។ ម្យ៉ាងទៀត ទិន្នន័យដែលមានក្នុងរបាយការណ៍ខាងលើនេះ បង្ហាញថាអត្រា នៃការស្លាប់ដោយសារការលង់ទឹក បានប្រែប្រួលក្នុងរយៈពេលជាច្រើនឆ្នាំ ហើយគេសង្កេតឃើញថា ក្នុងចំណោមនោះ បុរសមានអត្រាខ្ពស់ជាងស្ត្រី។ ទិន្នន័យនេះក៏បង្ហាញដែរថា ការលង់ទឹកប៉ះពាល់ដល់ក្រុមអាយុផ្សេងៗ ដោយក្នុងនោះមានកុមារអាយុ៤ឆ្នាំ និងមនុស្សពេញវ័យក្នុងវ័យ១៥ ដល់១៩ឆ្នាំ និង៦០ ដល់៦៩ឆ្នាំ គឺពួកគាត់មានភាពងាយរងគ្រោះ ឬហានិភ័យខ្ពស់។ តាមនិន្នាការប្រជាសាស្ត្រនេះ គូសបញ្ជាក់ពីតម្រូវការសម្រាប់គោលដៅអន្តរាគមន៍ចំពោះហានិភ័យជាក់លាក់ ដែលប្រឈមមុខទាំងកុមារតូច និងមនុស្សចាស់ ដែលអាចនឹងគ្រោះថ្នាក់លង់ទឹក ដោយសារកត្តាគ្រប់គ្រង និងត្រួតពិនិត្យមិនគ្រប់គ្រាន់ ការអប់រំអំពីសុវត្ថិភាពទឹកមានកម្រិត ហានិភ័យដោយសារប្រភេទមុខរបរ ឬសកម្មភាពកម្សាន្តនៅជុំវិញប្រភពទឹក[17]។

## ៣.២. បរិការណ៍នានា ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹកនៅកម្ពុជា

ការការពារ និងគ្រប់គ្រងការលង់ទឹកនេះ ត្រូវបានគេមើលឃើញថា ជាការងារមួយដែលនៅមានកម្រិតនៅឡើយនៅកម្ពុជា បើធៀបនឹងការងារក្នុងវិស័យផ្សេងៗទៀត។ ជាក់ស្តែង នេះជាលើកទីមួយ

[17] Global Health Estimated Data 2021_WHO

ដែលកម្ពុជាផ្តួចផ្តើមរៀបចំឱ្យមានផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក ដោយបានទទួលស្គាល់ថា វាជាបញ្ហាសុខភាពសាធារណៈមួយ ចាំបាច់ត្រូវដោះស្រាយបន្ទាន់។ ទោះជាបែបនេះក្តី ក៏កន្លងមកមានសកម្មភាព និងអន្តរាគមន៍ខ្លះៗ ពីក្រសួង ស្ថាប័នមួយចំនួនដូចជា៖

- **ក្រសួងសុខាភិបាល៖** ដោយសារការលង់ទឹកត្រូវបានចាត់ទុកជាបញ្ហាសុខភាពសាធារណៈ ដូច្នេះ នាយកដ្ឋានការពារសុខភាព បានអនុវត្តន៍ការងារសាកល្បងគម្រោងការពារ និងកាត់បន្ថយការលង់ទឹក នៅឆ្នាំ២០០៩ ដោយបានបណ្តុះបណ្តាលផ្នែកសុវត្ថិភាពទឹកនៅតំបន់បឹងទន្លេសាបចំនួន១០ឃុំ ក្នុងខេត្តកំពង់ឆ្នាំង។ នៅឆ្នាំ២០២៣ បានធ្វើការសិក្សាពីការលង់ទឹករបស់កុមារ ដែលជាធាតុចូលយ៉ាងសំខាន់ក្នុងរបាយការណ៍សកលរបស់អង្គការសុខភាពពិភពលោក។
- **ក្រសួងសាធារណការ និងដឹកជញ្ជូន៖** បានបណ្តុះបណ្តាល ស្តីពីការការពារការលង់ទឹកដល់សហគមន៍តាមផ្លូវទឹក។ ក្រសួងក៏បានបង្កើត និងដាក់ឱ្យប្រើប្រាស់ច្បាប់ ស្តីពីការដឹកជញ្ជូនផ្លូវទឹក ដែលបានអនុម័តនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤។
- **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួងការពារជាតិ៖** បានបង្កើត និងបណ្តុះ បណ្តាលក្រុមរុករក និងសង្គ្រោះតាំងពីឆ្នាំ២០២០ ជាញឹកញាប់ក្រុមនេះ នៅបន្តធ្វើលំហាត់សមយុទ្ធរុករក និងជួយសង្គ្រោះប្រជាជន និងប្រតិបត្តិការឆ្លើយតបពេលមានគ្រោះមហន្តរាយកើតឡើង។ កងរុករកសង្គ្រោះនេះ ក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងប្រតិបត្តិការផ្ទាល់រៀងរាល់ពេលមានគ្រោះ ទឹកជំនន់ជំម្តងៗ ជាពិសេស ទឹកជំនន់រហ័សដោយសារទឹកភ្លៀងនៅតំបន់នានាទូទាំងប្រទេសកម្ពុជា។
- **ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)៖** ក្រសួងអប់រំ យុវជននិងកីឡា បានយកចិត្តទុកដាក់លើសុខុមាលភាពរបស់សិស្សានុសិស្ស ដោយបានបញ្ចូលមុខវិជ្ជាអប់រំកាយទៅក្នុងកម្មវិធីសិក្សាជាតិ។ តាមរយៈអាទិភាពនេះ ក្រសួងបានសហការជាបន្តបន្ទាប់ជាមួយដៃគូដូចជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) អង្គការបេះដូងមាស (Hearts of Gold) តាំងពីឆ្នាំ២០០៦ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាលើ មុខវិជ្ជាសម្បទាបំណិន និងចរិយាសម្បទាដោយក្នុងនោះការអប់រំលើការហែលទឹកដល់សិស្ស ក៏ជាអាទិភាពចម្បងមួយផងដែរ។
- **កាកបាទក្រហមកម្ពុជា៖** កាកបាទក្រហមកម្ពុជា គឺជាស្ថាប័នមនុស្សធម៌ដែលជាជំនួយការដល់អាជ្ញាធរសាធារណៈ របស់រាជរដ្ឋាភិបាលលើវិស័យមនុស្សធម៌។ កាកបាទក្រហមកម្ពុជាបានបណ្តុះបណ្តាលផ្នែកសង្គ្រោះបឋម រួមទាំងការសង្គ្រោះបឋមនៅពេលទឹកជំនន់ និងពេលមានលង់ទឹកដល់ស្ថាប័នជាច្រើន រួមទាំងការបណ្តុះបណ្តាញអ្នកស្ម័គ្រចិត្តរបស់ខ្លួននៅតាមសហគមន៍ផងដែរ។
- **អង្គការសុខភាពពិភពលោក (WHO)៖** អង្គការសុខភាពពិភពលោកជាស្ថាប័នអង្គការសហប្រជាជាតិមួយដែលធ្វើការងារយ៉ាងសកម្មលើវិស័យការពារ និងគ្រប់គ្រងការលង់ទឹក ដោយមានការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុលើកការងារគ្រប់គ្រងទិន្នន័យ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងជំនាញនានារបស់រាជរដ្ឋាភិបាល។
- **អង្គការយូនីសេហ្វ (UNICEF)៖** បាន និងកំពុងធ្វើសកម្មភាពមួយចំនួនដូចជា សិក្សាស្វែងយល់ពីស្ថានភាពគោលនយោបាយ និងឯកសារគតិយុត្តពាក់ព័ន្ធនឹងការលង់ទឹក កសាងសមត្ថភាពលើការការពារ និងគ្រប់គ្រងការលង់ទឹក គាំទ្រដល់ការបណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពទឹក ជំនាញសង្គ្រោះជីវិត និងជំនាញហែលទឹកជាមូលដ្ឋាន អប់រំផ្សព្វផ្សាយ ផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុក្នុងភាពជាដៃគូ គាំទ្រសហគមន៍គោលដៅក្នុងការការពារ និងគ្រប់គ្រងការលង់ទឹកនៅកម្រិតសហគមន៍។

- **អង្គការហេបកូដកម្ពុជា (Helpcode Cambodia)៖** បានផ្តល់ចំណេះដឹងអំពីសុវត្ថិភាពទឹក ជំនាញសង្គ្រោះបឋម ជំនាញហែលទឹក និងការសង្គ្រោះដល់កុមារតាមសាលារៀន លោកគ្រូអ្នកគ្រូ មាតាបិតាសិស្ស អ្នកមើលថែទាំក្មេង សមាជិកសហគមន៍ បុគ្គលិកតាមតំបន់ទេសចណ៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីពាក់ពន្ធ័រៀបចំធ្វើផែនទីតំបន់ ដែលមានហានិភ័យខ្ពស់ក្នុងការលង់ទឹក និងធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកដឹកនាំ អនុត្តន៍ និងគាំទ្រយុទ្ធនាការ ចូលរួមជាមួយដៃគូរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សាលារៀន ដើម្បីបង្កើតបណ្តាញ និងតស៊ូមតិសម្រាប់ការកែលម្អវិធានការសុវត្ថិភាពជុំវិញទឹក និងនៅក្នុងទឹក រួមទាំងពង្រឹងគោលនយោបាយជាតិ ស្តីពីសុវត្ថិភាពទឹកសម្រាប់កុមារ និងសហគមន៍របស់ពួកគេ។
- **អង្គការហែលទឹកកម្ពុជា (HILE TEUK KAMPUCHEA)៖** បាន និងកំពុងមានសកម្មភាពមួយចំនួន ដូចជា ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពគ្រូបង្គោលផ្នែកសុវត្ថិភាពទឹក ជំនាញសង្គ្រោះជីវិតមនុស្សលង់ទឹក និងជំនាញហែលទឹកជាមូលដ្ឋាន អប់រំផ្សព្វផ្សាយដល់កុមារ ឪពុកម្តាយ អាណាព្យាបាល និងសហគមន៍អំពីវិធីសាស្ត្រការពារ បង្កើនភាពជាដៃគូ ជាមួយភាគីពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីហានិភ័យ នៃការលង់ទឹក។

## ៣.៣. កត្តានានា នៃភាពងាយរងគ្រោះ និងគោលនយោបាយ ស្តីពីការលង់ទឹក

### ៣.៣.១. កត្តានានា នៃភាពងាយរងគ្រោះ

ខាងក្រោមនេះ ជាកត្តាចម្បងៗ ដែលជាកាតាលីករ ឬមូលហេតុឱ្យមានការលង់ទឹកកើតមាន។ ការស្វែងយល់ និងវាយតម្លៃ ព្រមទាំងប្រមូលទិន្នន័យពីភាពងាយរងគ្រោះឱ្យបានជាក់លាក់វានឹងជាមូលដ្ឋានដើម្បីចាត់វិធានការ៖

**១.កត្តាភូមិសាស្ត្រ និងបរិស្ថាន៖** កម្ពុជាមានបណ្តាញទន្លេ បឹង និងទំនាបលិចទឹកយ៉ាងច្រើន ដូចជា៖ ទន្លេមេគង្គ និងបឹងទន្លេសាប រួមទាំងតំបន់ឆ្នេរផងដែរ។ ក្នុងអំឡុងរដូវវស្សា តំបន់នៅតាមដងទន្លេទាំងនេះ ងាយនឹងជន់លិច បង្កើនហានិភ័យ នៃការលង់ទឹក ជាពិសេស នៅតំបន់ជនបទ និងតំបន់ទំនាប រួមទាំង តំបន់ឆ្នេរ។ ក្រៅពីនេះ មានការកើនឡើងនូវប្រភេទទឹកជំនន់រហ័សដោយសារទឹកភ្លៀងនាប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលមានកើតមានឡើងនៅតំបន់មួយចំនួន ដែលមិនធ្លាប់មានបទពិសោធន៍រងទឹកជំនន់ពីមុនមក ជាពិសេស នៅតំបន់ខ្ពង់រាប និងជួរភ្នំនានានៅក្នុងប្រទេស។ ប្រភពទឹកផ្សេងៗទៀតដូចជា អូរ ស្ទឹង បឹង រួមទាំង ពាងទឹក អាងហែលទឹក ។ល។ ក៏ជាកន្លែងដែលអាចមានលង់ទឹកផងដែរ ដោយសារតែខ្វះការការពារ និងវិធានការប្រុងប្រយ័ត្នជាមុន។ ដូចគ្នានេះដែរ គេសង្កេតឃើញថាមានការជីកស្រះធំៗជាច្រើន ថែមទៀតនៅតាមសហគមន៍មូលដ្ឋាននានា តែមិនមានបំពាក់នូវវិធានការការពារជាក់លាក់នោះទេ។

**២.វិធានការគ្រប់គ្រងត្រួតពិនិត្យសុវត្ថិភាព៖** ជារឿយៗកុមារ ជាពិសេសកុមារដែលមានអាយុក្រោម៥ឆ្នាំ នៅមិនទាន់មានការគ្រប់គ្រង និងមើលថែទាំឱ្យបានហ្មត់ចត់នៅកន្លែងមានប្រភពទឹកអាចលង់បាន។ កង្វះការត្រួតពិនិត្យជាប្រចាំនេះ ធ្វើឱ្យពួកគេងាយរងគ្រោះទៅនឹងការលង់ទឹកដោយចៃដន្យ មិនថាតែក្នុងរដូវទឹកជំនន់ ឬរដូវប្រាំងនោះទេ។

មុខរបរសំខាន់មួយ នៃជីវភាពប្រជាជនកម្ពុជាគឺពឹងផ្អែកលើការនេសាទ កសិកម្ម និងសកម្មភាពទាក់ទងនឹងទឹកផ្សេងៗទៀត សម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ កត្តានេះជំរុញឱ្យគេមានអន្តរកម្មញឹកញាប់ជាមួយកន្លែងមានទឹក ហើយខ្វះការប្រុងប្រយ័ត្ន ដែលបង្កើនហានិភ័យ នៃការលង់ទឹក ជាពិសេសនៅពេលដែលមិនទាន់មានវិធានការសុវត្ថិភាព។

៣.**ជំនាញហែលទឹក និងសុវត្ថិភាព៖** មនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជា ទាំងនៅទីក្រុង និងជនបទ គឺពួកគេខ្វះជំនាញហែលទឹកជាមូលដ្ឋាន។ លើសពីនេះទៀត ចំណេះដឹង និងជំនាញសង្គ្រោះនៅពេលមានមនុស្សលង់ទឹកក៏នៅមានកម្រិតដែរ។ ការណ៍នេះ បានកំហិតឱ្យមានការលំបាកដល់បុគ្គលម្នាក់ៗ ក្នុងការជួយសង្គ្រោះខ្លួនឯង ឬអ្នកដទៃ ក្នុងពេលមានគ្រោះអាសន្ននានា ទាក់ទងនឹងការលង់ទឹក។

៤.**ការយល់ដឹង និងការអប់រំ៖** ចំណេះដឹងទូទៅ ការអប់រំអំពីសុវត្ថិភាពទឹក និងការការពារការលង់ទឹកគឺមានកម្រិត។ សហគមន៍ជាច្រើនមិនមានលទ្ធភាពទទួលបានព័ត៌មាន ឬការបណ្តុះបណ្តាលអំពីវិធីការពារការលង់ទឹក និងការសង្គ្រោះ។ លើសពីនេះទៀត សាធារណជនក៏មិនសូវមានការយកចិត្តទុកដាក់ឱ្យបានខ្ពស់ពីសារៈសំខាន់ និងហានិភ័យ នៃបញ្ហាលង់ទឹកនៅឡើយ។

៥.**ហេដ្ឋារចនាសម្ព័ន្ធ និងវិធានការសុវត្ថិភាព៖** តំបន់ជនបទជាច្រើនខ្វះហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដូចជារបាំងជុំវិញអណ្តូង ស្រះ ស្លាកសញ្ញាសម្គាល់សុវត្ថិភាព ស្លាកសញ្ញាអប់រំពីសុវត្ថិភាពការលង់ទឹក និងកន្លែងមានប្រភពទឹកផ្សេងៗ។ លើសពីនេះ ក៏មានការខ្វះខាតឧបករណ៍សង្គ្រោះជីវិត និងបុគ្គលិកដែលមានការបណ្តុះបណ្តាលដើម្បីឆ្លើយតបនឹងឧបទ្ទវហេតុគ្រោះថ្នាក់លង់ទឹកតាមរូបភាពផ្សេងៗ។

៦.**ការទទួលទានគ្រឿងស្រវឹង**[18]**៖** គ្រឿងស្រវឹងបានកាត់បន្ថយសមត្ថភាពវិនិច្ឆ័យ និងការគ្រប់គ្រងខ្លួនឯងដែលបានបង្កើនហានិភ័យ នៃឧបទ្ទវហេតុលង់ទឹក។ ការទទួលទានគ្រឿងស្រវឹងនៅជិតកន្លែងមានប្រភពទឹក អាចកើតមានក្នុងសហគមន៍មួយចំនួនផងដែរ។

៧.**មធ្យោបាយធ្វើដំណើរតាមផ្លូវទឹក៖** ដោយហេតុថាប្រទេសកម្ពុជាសម្បូរដោយប្រភពទឹកទន្លេ ស្ទឹង បឹងបួ។ ដូច្នេះ ជាញឹកញាប់មនុស្សជាច្រើនប្រើប្រាស់ទូក ដើម្បីធ្វើដំណើរ និងប្រកបរបរនានា ឬករណីសិស្សសាលាត្រូវធ្វើដំណើរតាមផ្លូវទឹក ទៅមកសាលារៀន។ ក្នុងករណីនេះ ជាញឹកញាប់គេសង្កេតឃើញថាវិធានការសុវត្ថិភាពនៅមិនគ្រប់គ្រាន់ដូចជា មិនមានអាវពោងសុវត្ថិភាព ការផ្ទុកលើសចំណុះ មធ្យោបាយធ្វើដំណើរចាស់ទ្រុឌទ្រោម និងមិនគ្រប់លក្ខណៈបច្ចេកទេស បរិបាល (អ្នកបើកបរនាវា) គ្មានវិជ្ជាជីវៈរួមចំណែកធ្វើឱ្យមានគ្រោះថ្នាក់លង់ទឹកកើតមានឡើង។

៨.**ទឹកជំនន់ និងគ្រោះមហន្តរាយនានា៖** ប្រទេសកម្ពុជាធ្លាប់ជួបគ្រោះទឹកជំនន់ដ៏អាក្រក់ និងភ្លៀងធ្លាក់ខ្លាំងជាពិសេសនៅរដូវមូសុង។ ទឹកជំនន់ហៀសភ្លាមៗ ដែលមិនបានត្រៀមទុកជាមុន អាចបង្កឧបទ្ទវហេតុលង់ទឹកទាំងនៅទីក្រុង និងជនបទ ជាពិសេសតំបន់មិនធ្លាប់មានទឹកជំនន់ពីមុនមក។

៩.**ការប្រតិបត្តិ និងជំនឿមួយចំនួន៖** ក្នុងករណីខ្លះ ការប្រតិបត្តិតាមវប្បធម៌ ឬជំនឿមិនសមហេតុផល អាចបង្កឱ្យមានការមិនទុកចិត្តក្នុងការប្រើប្រាស់ឧបករណ៍ជំនួយការពារជីវិត ឬការប្រកាន់ខ្ជាប់គោលការណ៍ណែនាំប្រកបដោយសុវត្ថិភាព ដែលការប្រតិបត្តិបែបនេះ បង្កើនហានិភ័យនៃការលង់ទឹក ដែលមានករណីជាច្រើន បានអះអាងថា ការដាក់អាវពោងសុវត្ថិភាព ឬមានវិធានការការពារជាមុនវាជាប្រផ្នូលមិនល្អ។

[18] Global report on drowning, Preventing a leading killer, WHO 2014

១០.ការតាំងលំនៅឆ្ងាយៗពីភូមិឋាន ឬដាច់ស្រយាល៖ នាប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍលឿនគួរឱ្យកត់សម្គាល់។ ក្នុងនោះ ការតាំងទីលំនៅតាមតំបន់ថ្មីៗ និងនៅដាច់ឆ្ងាយពីភូមិឋានក៏កើតមានឡើងច្រើនផងដែរ។ នៅពេលមានទឹកជំនន់កើតឡើង អ្នកតាំងលំនៅឆ្ងាយៗដាច់ពីគេទាំងនោះអាចប្រឈមនឹងការលង់ទឹកដោយសារពួកគេមិនទទួលបានព័ត៌មានព្រមាននានា។ ម៉្យាងទៀតក្រុមអន្តរាគមន៍ក៏មិនបានទទួលដំណឹងពីពួកគេបានពេញលេញក្នុងករណីខ្លះ។ ជាពិសេសក្នុងនៅតំបន់ដែលមានទឹកជំនន់ហ័ស ទឹកភ្លៀងជាញឹកញាប់ និងបរិមាណច្រើនខុសពីពេលមុនៗ។

### ៣.៣.២. គោលនយោបាយ និងកម្មវិធីការងារអាទិភាព

- គោលនយោបាយ និងការអនុវត្តនៅមានកម្រិត

១.គោលនយោបាយការពារការលង់ទឹក៖ គោលនយោបាយជាក់លាក់ និងទូលំទូលាយសម្រាប់ការការពារ និងគ្រប់គ្រងការលង់ទឹកនៅមានកម្រិត មិនជាក់លាក់ និងមិនទាន់ច្បាស់លាស់ដែលនាំឱ្យមានគម្លាតក្នុងការអនុវត្តវិធានការការពារសមស្រប និងចាំបាច់នានា។ ដូចបានបញ្ជាក់ខាងលើរួចមក ជាលើកទីមួយដែលប្រទេសកម្ពុជាបានផ្តួចផ្តើមរៀបចំឱ្យមានផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក។ ប្រទេសកម្ពុជាមិនទាន់មានគោលនយោបាយជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក ដែលមានលក្ខណៈអន្តរវិស័យគ្រប់ជ្រុងជ្រោយនៅឡើយទេ ប៉ុន្តែកម្ពុជាមានឯកសារគតិយុត្តតាមវិស័យមួយចំនួនរួចមកហើយ ដូចជាច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ គោលនយោបាយ ស្តីពីសាលាកុមារមេត្រី និងកម្មវិធីសិក្សាលម្អិត ស្តីពីការអប់រំកាយ និងកីឡាក្នុងវិស័យអប់រំ សារាចរណែនាំ ស្តីពីការងារគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក (ឆ្នាំ២០០០) សារាចរណែនាំ ស្តីពីការគ្រប់គ្រងវិស័យនាវាចរណ៍សមុទ្រ (ឆ្នាំ១៩៩៩) នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន។ល។

២.បទប្បញ្ញត្តិ និងគតិយុត្ត ស្តីពីសុវត្ថិភាពទឹកនៅក្នុងក្របខ័ណ្ឌច្បាប់៖ អវត្តមាន នៃច្បាប់ និងបទប្បញ្ញត្តិពីសុវត្ថិភាពទឹកជាក់លាក់ និងច្បាស់លាស់ ជាពិសេសទាក់ទងនឹងការសាងសង់ ឬការប្រើប្រាស់ប្រភពទឹកដូចជាទន្លេ ស្ទឹង ស្រះ បឹង និងអាងស្តុកទឹក។ គម្លាតនេះ មានក្នុងរូបភាពនានា ដូចជា បទប្បញ្ញត្តិមិនគ្រប់គ្រាន់ ស្តីពីការហ៊ុមព័ទ្ធការពារ ការកំណត់តំបន់មានទឹកដែលអាចលង់បាន និងការធានាពីសុវត្ថិភាពសាធារណៈនៅកន្លែងមានទឹកអាចលង់បាន។ ដូចគ្នានេះដែរ គឺនៅមិនទាន់មានបទប្បញ្ញត្តិ និងការអនុវត្តបានគ្រប់គ្រាន់លើការប្រើប្រាស់អាវពោងសុវត្ថិភាព ឬវិធានការសុវត្ថិភាពផ្សេងទៀត សម្រាប់អ្នកដែលធ្វើការនៅក្នុង ឬនៅបរិវេណជុំវិញទឹក (ឧទាហរណ៍ អ្នកនេសាទ អ្នកជិះទូក ឬសាឡាង) បានរួមចំណែកដល់ហានិភ័យខ្ពស់ នៃឧបទ្ទវហេតុលង់ទឹកនៅក្នុងដែនប្រតិបត្តិការងារ។

៣.សមាហរណកម្មការការពារលង់ទឹកក្នុងគោលនយោបាយជាតិ សុខភាព និងសុវត្ថិភាព៖ គោលនយោបាយសុខភាព និងសុវត្ថិភាពដែលមានស្រាប់ រួមទាំងផែនការសុខភាពកុមារ ឬផែនការគ្រប់គ្រងគ្រោះមហន្តរាយ មិនមានរួមបញ្ចូល និងរំលេចឱ្យបានពេញលេញ និងជាក់លាក់នូវវិធានការការពារការលង់ទឹកជាបញ្ហាអាទិភាពនៅឡើយទេ។

**៤.ផែនការគ្រប់គ្រងគ្រោះមហន្តរាយមិនទាន់មានរំលេចពីការការពារ និងគ្រប់គ្រងការលង់ទឹកឱ្យបានជាក់លាក់៖** ហានិភ័យ នៃការលង់ទឹកក្នុងអំឡុងពេលទឹកជំនន់ គឺនៅមិនទាន់បានបញ្ចូលក្នុងផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសឱ្យបានជាក់លាក់នៅឡើយ។ ចំពោះផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតប សង្គ្រោះបន្ទាន់គ្រោះមហន្តរាយ។ ការលង់ទឹកគឺជាការពិចារណាសំខាន់បន្ទាប់ក្នុងផែនការត្រៀមបម្រុងទឹកជំនន់ និងគ្រោះថ្នាក់ដែលបង្កដោយទឹក។

- **គម្រោង ឬកម្មវិធីការងារនៅមានកម្រិត**

**១.ការយល់ដឹងជាសាធារណៈ និងការចូលរួមរបស់សហគមន៍មិនបានគ្រប់គ្រាន់៖** មានការខ្វះខាត នៃយុទ្ធនាការលើកកម្ពស់ការយល់ដឹងតាមសហគមន៍ ស្តីពីសុវត្ថិភាពទឹក និងការការពារការលង់ទឹកជាពិសេសនៅតំបន់ជនបទ ដែលងាយរងគ្រោះ រួមទាំងតំបន់ដែលទើបកើតមានទឹកជំនន់រហ័សនាប៉ុន្មានឆ្នាំចុងក្រោយនេះ។ គម្រោង ឬកម្មវិធីការងារដែលមានស្រាប់ មិនគ្រប់គ្រាន់ទៅដល់ប្រជាជនដែលប្រឈមហានិភ័យជាងគេដូចជាកុមារ អ្នកថែទាំ និងមនុស្សដែលរស់នៅក្បែរកន្លែងមានទឹកនោះទេ។ ជាញឹកញាប់ គេសង្កេតឃើញថានៅតំបន់ជនបទនានា កុមារត្រូវបានឪពុកម្តាយទុកឱ្យនៅជាមួយជីដូនជីតានៅផ្ទះ។ ដូច្នេះ គម្រោង ឬកម្មវិធីការងារគួរធ្វើការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមគោលដៅទាំងនេះផងដែរ។

**២.ការអប់រំអំពីសុវត្ថិភាពទឹកនៅមានកម្រិត៖** ការអប់រំអំពីសុវត្ថិភាពទឹកមិនទាន់បានធ្វើសមាហរណកម្មទៅក្នុងកម្មវិធីសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈនៅឡើយ។ ខណៈពេលដែលសាលារៀនមួយចំនួនតូចអាចផ្តល់ការអប់រំជាមូលដ្ឋានអំពីសុវត្ថិភាពទឹក ឬមេរៀនហែលទឹកក៏ដោយ ក៏មិនមានស្តង់ដាជាក់លាក់នៅទូទាំងប្រទេសដើម្បីបង្រៀនសិស្សានុសិស្សអំពីចំណេះដឹងការការពារ និងការសង្គ្រោះការលង់ទឹក នេះនៅឡើយ។

**៣.កង្វះខាតឆ្មាំជីវិត[19] និងអ្នកសង្គ្រោះបឋម៖** ព្រះរាជាណាចក្រកម្ពុជាមានបុគ្គលិកជំនាញផ្នែកសង្គ្រោះបឋម និងអ្នកជំនាញផ្នែកសុវត្ថិភាពទឹក ដែលបានទទួលការបណ្តុះបណ្តាលមិនទាន់គ្រប់គ្រាន់នៅឡើយ។ កម្មវិធីផ្តល់ការបណ្តុះបណ្តាលដល់សមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋាន អំពីបច្ចេកទេសជាមូលដ្ឋានក្នុងការសង្គ្រោះបឋម និងការឆ្លើយតបបន្ទាន់ចំពោះឧបទ្ទវហេតុលង់ទឹកក៏នៅមានកម្រិត។

**៤.កង្វះខាតបរិក្ខារហែលទឹកសាធារណៈ និងការឃ្លាំមើលតំបន់មានទឹកអាចលង់បាន៖** សហគមន៍ជាច្រើន ជាពិសេសនៅតំបន់ជនបទ ខ្វះកន្លែងហែលទឹកសាធារណៈដែលមានសុវត្ថិភាព ដែលកុមារ និងមនុស្សធំ អាចរៀនហែលទឹកក្នុងបរិស្ថានសមស្រប។ កុមារទទួលបានការរៀនហែលទឹកមានកម្រិត ដែលបានកាត់បន្ថយឱកាសសម្រាប់ការអភិវឌ្ឍជំនាញសង្គ្រោះជីវិត ។

**៥.ការប្រមូលទិន្នន័យ និងការស្រាវជ្រាវអំពីការលង់ទឹកមានកម្រិត៖** មានការខ្វះខាតទិន្នន័យគ្រប់ជ្រុងជ្រោយអំពីឧបទ្ទវហេតុលង់ទឹក ជាពិសេសនៅតាមទីជនបទ និងតំបន់ដាច់ស្រយាល។ ដោយគ្មានទិន្នន័យជាក់លាក់ ពិបាកក្នុងការកំណត់តំបន់ដែលមានហានិភ័យខ្ពស់ តាមដានប្រសិទ្ធភាព នៃកិច្ចអន្តរាគមន៍ និងបង្កើតកម្មវិធីគោលដៅការពារការលង់ទឹក។ ជាញឹកញាប់ របាយការណ៍ និងការកត់ត្រាករណីលង់ទឹកនៅមិនទាន់ញែកដាច់រវាងការស្លាប់ ឬគ្រោះថ្នាក់លង់ទឹកនៅឡើយ។

[19] ឆ្មាំជីវិត៖ អ្នកចាំរក្សាជីវិត (វចនានុក្រមខ្មែរ ២០២២)

**៦.ប្រព័ន្ធប្រកាសជូនដំណឹងព្រមានជាមុនអំពីគ្រោះទឹកជំនន់ និងមុខសញ្ញាគ្រោះថ្នាក់ដោយសារទឹកនៅមានកម្រិត៖** ប្រព័ន្ធប្រកាសជូនដំណឹងព្រមានជាមុននៅមិនទាន់បានគ្របដណ្តប់ឱ្យបានជាក់លាក់ និងទាំងស្រុងដល់គ្រប់មូលដ្ឋានងាយរងគ្រោះដោយគ្រោះទឹកជំនន់។ លើសពីនេះទៀត ក៏នៅមានគម្លាតក្នុងការចាត់វិធានការ សកម្មភាពត្រៀម និងឆ្លើយតបជាក់លាក់ក្រោយពេលមានព័ត៌មានព្រមាននានា។

**៧.ការសម្របសម្រួលក្នុងចំណោមក្រសួងនានារបស់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធនៅមានកម្រិត៖** ការសម្របសម្រួលឆ្លងវិស័យរវាងក្រសួងសុខាភិបាល ក្រសួងអប់រំយុវជន និងកីឡា ក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំងភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយផ្សេងៗ មានគម្លាតនៅឡើយ ក្នុងការចាត់វិធានការលើការគ្រប់គ្រង និងដោះស្រាយការលង់ទឹក។ ដោយគ្មានវិធីសាស្ត្ររួម កិច្ចខិតខំប្រឹងប្រែងការពារការលង់ទឹកនៅខ្វះការរួមផ្សំគ្នា និងមិនមានលក្ខណៈជាប្រព័ន្ធ។

**៨.ថវិកា និងធនធានមានកម្រិតសម្រាប់កម្មវិធីការពារ និងគ្រប់គ្រងការលង់ទឹក៖** នៅកម្ពុជាជារឿយៗ កម្មវិធីការពារការលង់ទឹក ទទួលបានធនធានហិរញ្ញវត្ថុនៅមានកម្រិត និងពឹងផ្អែកលើគម្រោងរយៈពេលខ្លី ដែលគាំទ្រដោយម្ចាស់ជំនួយអន្តរជាតិ ហើយមិនមានយន្តការផ្តល់មូលនិធិប្រកបដោយនិរន្តរភាព ដើម្បីគាំទ្រដល់ការធ្វើអន្តរាគមន៍រយៈពេលវែងនោះទេ។

## ៤. យុទ្ធសាស្ត្រ និងកម្មវិធីការងារអាទិភាព

### ៤.១ យុទ្ធសាស្ត្រអាទិភាពទាំង៤ សម្រាប់ការពារ និងគ្រប់គ្រងការលង់ទឹក

យុទ្ធសាស្ត្រជាទិសដៅចម្បងៗខាងក្រោមនេះ ត្រូវបានដាក់ចេញ ដើម្បីដោះស្រាយ ឆ្លើយតបនិងកាត់បន្ថយចំពោះភាពងាយរងគ្រោះនានា ដែលបានវិភាគ និងរកឃើញដូចខាងលើ។



## ៤.២ កម្មវិធីការងារអាទិភាព និងសកម្មភាពចម្បងៗ

| កម្មវិធីការងារអាទិភាព | សូចនាករ[20] | សកម្មភាពចម្បងៗ |
|---|---|---|
| **យុទ្ធសាស្ត្រទី១៖ អភិវឌ្ឍន៍ និងលើកកម្ពស់ការអនុវត្តក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនៃការការពារនិងគ្រប់គ្រងការលង់ទឹក** | | |
| **កម្មវិធីការងារអាទិភាពទី១.១៖** បង្កើតគោលនយោបាយ ច្បាប់ ឬបញ្ញត្តិ នានាស្តីពីការពារនិងគ្រប់គ្រងការលង់ទឹកថ្នាក់ជាតិ និងក្រោមជាតិ | • ចំនួនឯកសារក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត នៃការការពារ និងគ្រប់គ្រងការលង់ទឹកត្រូវបានរៀបចំចងក្រង<br>• ឯកសារក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត នៃការការពារនិងគ្រប់គ្រងការលង់ទឹកមានគុណភាព និងឆ្លើយតបតាមបរិបទតម្រូវការ ជាក់លាក់នៅកម្ពុជា ជាពិសេសគឺភាពងាយរងគ្រោះនានា។ | ១-ធ្វើការសិក្សានិងវិភាគគម្លាតគោលនយោបាយ ស្តីពីការលង់ទឹក ដើម្បីជាមូលដ្ឋានរៀបចំចង ក្រងគោលនយោបាយការការពារ និងគ្រប់គ្រងការលង់ទឹកឱ្យបានសមស្រប និងដាក់ឱ្យអនុវត្តន៍<br>២-ចងក្រងគោលនយោបាយ និងបទបញ្ញត្តិជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក<br>៣-ប្រកាសដាក់ឱ្យប្រើប្រាស់គោលនយោបាយ និងបទបញ្ញត្តិនានា ដែលបានដាក់ចេញ<br>៤-បង្កើតគោលការណ៍ណែនាំ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក។ |
| **កម្មវិធីការងារអាទិភាពទី១.២៖** | • ចំនួននៃកិច្ចប្រជុំ ឬសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយស្តីពីឯកសារក្របខ័ណ្ឌ | ៥-ធ្វើការប៉ាន់ប្រមាណពីតម្រូវការ នៃការបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយ និងរៀបចំផែនការដាក់លាក់សម្រាប់ |

[20] សូចនាករលើកឡើងនាពេលនេះ ជាសូចនាកបែបគុណភាព ចំពោះសូចនាកបែបបរិមាណគឺនឹងត្រូវរៀបចំក្រោយពីធ្វើការសិក្សាទិន្នន័យដើមគ្រា និងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ។

| | | |
|---|---|---|
| ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលពីក្របខ័ណ្ឌច្បាប់គោលនយោបាយលិខិតបទដ្ឋានគតិយុត្ត នៃការការពារ និងគ្រប់គ្រងការលង់ទឹក ដល់តួអង្គពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្ត | ច្បាប់គោលនយោបាយលិខិតបទដ្ឋានគតិយុត្តនៃការការពារ និងគ្រប់គ្រងការលង់ទឹក<br>• ចំនួនអ្នកចូលរួមជាក់លាក់បានយល់ជ្រួតជ្រាបអំពីខ្លឹមសារ និងទិសដៅ នៃឯកសារក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនៃការការពារ និងគ្រប់គ្រងការលង់ទឹកដែលបានផ្សព្វផ្សាយ។ | ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ<br>៦-រៀបចំចងក្រងឯកសារនិងឧបករណ៍ វិធីសាស្ត្រ និងមេរៀននានាតាមរូបភាពផ្សេងៗតាម តម្រូវការជាក់លាក់និងមធ្យោបាយសមស្រប<br>៧-រៀបចំវគ្គបណ្តុះបណ្តាល និងមធ្យោបាយផ្សព្វផ្សាយនានាផ្អែកតាមបរិបទ និងតម្រូវការជាក់លាក់ ដើម្បីឱ្យការអប់រំផ្សព្វផ្សាយទាំងនោះ មានប្រសិទ្ធភាពខ្ពស់។ |
| **កម្មវិធីការងារអាទិភាពទី១.៣៖** បន្តអភិវឌ្ឍក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត នៃការការពារ និងគ្រប់គ្រងការលង់ទឹកថ្នាក់ជាតិ និងក្រោមជាតិ។ | • ចំនួនវេទិកា ពិគ្រោះយោបល់ក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនៃការការពារនិងគ្រប់គ្រងការលង់ទឹក<br>• ចំនួនរបាយការណ៍វិភាគ វាយតម្លៃក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត នៃការការពារនិងគ្រប់គ្រងការលង់ទឹក<br>• ចំនួនករណីសិក្សា និងរបាយការណ៍ស្រាវជ្រាវអំពីក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត នៃការការពារ និងគ្រប់គ្រងការលង់ទឹក។ | ៨-បង្កើតឱ្យមានវេទិកាពិគ្រោះយោបល់លើគោលនយោបាយ និងបញ្ញត្តិនានាស្តីពី ការការពារ និងគ្រប់គ្រងការលង់ទឹករវាងភាគីពាក់ព័ន្ធឱ្យបានទៀងទាត់ ដើម្បីជាមូលដ្ឋានកែសម្រួល និងអភិវឌ្ឍន៍បន្ត<br>៩-បន្តធ្វើការវាយតម្លៃ និងសិក្សាស្រាវជ្រាវលើការអនុវត្ត និងបន្តអភិវឌ្ឍ (Research and Development)<br>១០-ចងក្រងជាករណីសិក្សានានា ស្តីពីការអនុវត្តល្អសម្រាប់ជាមូលដ្ឋាន អប់រំផ្សព្វផ្សាយបន្ត។ |

| យុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការផ្តល់សេវាសុខភាព ការអប់រំផ្សព្វផ្សាយ ការយល់ដឹង ការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថងាយរងគ្រោះនានា ដើម្បីការពារ និងគ្រប់គ្រងការលង់ទឹក | | |
|---|---|---|
| **កម្មវិធីការងារអាទិភាពទី២.១ ៖** បង្កើត និងបណ្តុះបណ្តាលក្រុមអន្តរាគមន៍សង្គ្រោះរបស់ក្រសួងសុខាភិបាល | • ចំនួនរបាយការណ៍វិភាគតម្រូវការបណ្តុះបណ្តាល និងការសិក្សាពីរចនាសម្ព័ន្ធស្ថាប័នដើម្បីរៀបចំក្រុមឆ្លើយតបអន្តរាគមន៍របស់ក្រសួង<br>• ចំនួនឯកសារបណ្តុះបណ្តាល ដែលឆ្លើយតបនឹងបរិបទនៅកម្ពុជា ជាពិសេសគឺឆ្លើយតបនឹងប្រភេទនានា នៃហានិភ័យនិងភាពងាយរងគ្រោះនៃការលង់ទឹក<br>• ចំនួនវគ្គបណ្តុះបណ្តាលបានអនុវត្ត<br>• ចំនួនអ្នកចូលរួមទទួលបានចំណេះដឹងពីការការពារ និងគ្រប់គ្រងការលង់ទឹក។ | ១-ធ្វើការសិក្សាវិភាគពីរចនាសម្ព័ន្ធ និងមុខងារដែលមានស្រាប់ជាពិសេសក្រុមការងារឆ្លើយតបរហ័សរបស់ក្រសួងសុខាភិបាល អំពីតម្រូវការក្នុងការកែសម្រួលនិតិវិធីការងារ និងការបណ្តុះបណ្តាលបន្ថែមអំពីអន្តរាគមន៍ និងសង្គ្រោះអាយុជីវិតពេលលង់ទឹក។<br>២-ចងក្រងឯកសារបណ្តុះបណ្តាលជាក់លាក់ ដើម្បីបើកវគ្គបណ្តុះបណ្តាល<br>៣-បន្តពិនិត្យ និងកែលម្អឯកសារបណ្តុះបណ្តាលឱ្យបានទៀងទាត់។ |
| **កម្មវិធីការងារអាទិភាពទី២.២ ៖** យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ | • ចំនួនរបាយការណ៍សិក្សាស្រាវជ្រាវអំពីចរិកលក្ខណៈ នៃហានិភ័យ និងភាពងាយរងគ្រោះ ដោយការលង់ទឹកនៅកម្ពុជា<br>• ចំនួនរបាយការណ៍សិក្សាអំពីវិធីសាស្ត្រផ្សព្វផ្សាយសមស្របនិងមានប្រសិទ្ធភាព | ៤-ធ្វើការសិក្សាស្រាវជ្រាវស្វែងយល់ឱ្យបានជាក់លាក់អំពីការលង់ទឹកនៅកម្ពុជា (ចរិកលក្ខណៈនៃហានិភ័យ ភាពងាយរងគ្រោះ ទិន្នន័យទីតាំងប្រឈម និងងាយរងគ្រោះនានា មធ្យោបាយសមស្របសម្រាប់អប់រំផ្សព្វផ្សាយ)<br>៥-បង្កើតសម្ភារៈ និងមធ្យោបាយអប់រំពាក់ព័ន្ធសមស្រប នឹងវប្បធម៌ និងបរិបទជាក់ស្តែងដែលមាន (វិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្តាញសង្គមនានា អប់រំផ្ទាល់តាមសាលារៀន តាមសហគមន៍...) |

| | | |
|---|---|---|
| | • ចំនួនយុទ្ធនាការផ្សព្វផ្សាយតាមរូបភាពផ្សេងៗរួមទាំងសម្ភារៈ ឧបករណ៍ វិធីសាស្ត្រផ្សព្វផ្សាយ<br>• ចំនួនឯកសារនានាសម្រាប់អប់រំផ្សព្វផ្សាយ<br>• ចំនួនរបាយការណ៍បញ្ជាក់ពីការផ្លាស់ប្តូរឥរិយាបទ និងអកប្បកិរិយារបស់ក្រុមគោលដៅចំពោះការការពារ និងគ្រប់គ្រងការលង់ទឹក។ | ៦-រៀបចំព្រឹត្តិការណ៍ឬសកម្មភាពផ្សព្វផ្សាយតាមសហគមន៍ (សាលារៀន ការជួបជុំក្នុងមូលដ្ឋាន)<br>៧-យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ តាមរូបភាព និងមធ្យោបាយផ្សេងៗ ដោយផ្សារភ្ជាប់នឹងយន្តការពិនិត្យតាមដានវាយតម្លៃពីលទ្ធផល<br>៨-បង្កើតជាពិពណ៌ និងការតាំងបង្ហាញនានាអំពីការការពារ និងគ្រប់គ្រងការលង់ទឹកនៅតាមកម្មវិធីជាតិចម្បងៗនានាដែលពាក់ព័ន្ធ ជាពិសេស ក្នុងទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ បុណ្យអុំទូក...ជារៀងរាល់ឆ្នាំ។<br>៩-បញ្ជ្រាបការអប់រំផ្សព្វផ្សាយអំពីការការពារ និងការគ្រប់គ្រងការលង់ទឹកទៅក្នុងកម្មវិធីអប់រំ។ |
| **កម្មវិធីការងារអាទិភាពទី២.៣ ៖** លើកកម្ពស់ការអនុវត្តឥរិយាបថសុវត្ថិភាពនៅជិតកន្លែងមានទឹកអាចលង់បាន និងអំឡុងរដូវទឹកជំនន់ | • ចំនួនគ្រូបង្គោលដែលទទួលការបណ្តុះបណ្តាល<br>• ចំនួនគ្រូបង្គោលធ្លាប់ទទួលការបណ្តុះបណ្តាលបានយល់ជ្រួតជ្រាប និងអាចបណ្តុះបណ្តាលបន្តបានយ៉ាងសមស្រប<br>• ចំនួនសកម្មភាពអនុវត្តជាក់ស្តែង ដើម្បីហ៊ុមព័ទ្ធស្រះ និងប្រភពទឹកនានា<br>• ចំនួនសម្ភារៈ ឧបករណ៍ ដែលបានប្រគល់ជូនសហគមន៍ និងក្រុមគោលដៅ | ១០-បណ្តុះបណ្តាលគ្រូបង្រៀន ឬគ្រូបង្គោល ដើម្បីផ្តល់មេរៀនសុវត្ថិភាពទឹក ជំនាញសង្គ្រោះបឋម និងជំនាញហែលទឹកនៅតាមស្ថាប័នពាក់ព័ន្ធនានា<br>១១-យុទ្ធនាការធ្វើរបងហ៊ុមព័ទ្ធការពារនៅតាមប្រភពទឹកនានាដែលអាចលង់បាន<br>១២-អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល ដាក់លាក់ដល់អ្នកមើលថែទាំងក្មេងៗ នៅតាមសហគមន៍ពីវិធីការពារ និងសង្គ្រោះពេលលង់ទឹក<br>១៣-ផ្តល់សម្ភារៈ ឧបករណ៍នានាចាំបាច់សម្រាប់ការពារ និងសង្គ្រោះពេលមានករណីលង់ទឹក |

| | | |
|---|---|---|
| | • សហគមន៍ និងក្រុមដៅចេះប្រើ និងបានប្រើប្រាស់សម្ភារៈ និងឧបករណ៍ ដែលបានប្រគល់ជូន<br>• ចំនួនទស្សកិច្ចសិក្សា និងចំណេះដឹង ចំណេះធ្វើទទួលបានដោយអ្នកទៅទស្សនៈកិច្ចសិក្សា<br>• ចំនួនសកម្មភាពឬវិធានការដាក់លាក់ដែលបានអនុវត្តក្រោយពីទស្សនៈកិច្ចសិក្សា។ | ១៤-ទស្សនកិច្ចសិក្សាដោយក្រុមគោលដៅ និងគ្រូបង្គោលស្តីពីការលើកកម្ពស់ការផ្តល់សេវាអប់រំផ្សព្វផ្សាយ ការផ្លាស់ប្តូរឥរិយាបថ និងការគ្រប់គ្រងការលង់ទឹក។ |
| **កម្មវិធីការងារអាទិភាពទី២.៤ ៖** រៀបចំការបង្ហាត់ហែលទឹក និងបង្ហាត់កិច្ចសង្គ្រោះ ដោយសហការជាមួយភាគីពាក់ព័ន្ធ | • ចំនួនអ្នកបានទទួលការបង្ហាត់ហែលទឹក និងឯកសារមេរៀនសម្រាប់បង្ហាត់<br>• ចំនួនអ្នកដែលធ្លាប់ទទួលការបង្ហាត់ និងអាចហែលបានជាក់ស្តែងតាមប្រភេទទីតាំង និងស្ថានភាពនីមួយៗ<br>• ចំនួនអ្នកទទួលបានការបណ្តុះបណ្តាលពីរបៀបសង្គ្រោះ និងអាចអនុវត្តន៍ បានជាក់ស្តែង<br>• ចំនួនមេរៀន និងបច្ចេកទេសសង្គ្រោះដែលសមស្រប<br>• ចំនួនសមាជិកសហគមន៍ ដែលបានអនុវត្តន៍ការត្រៀម និងឆ្លើយតបជាក់លាក់ក្រោយទទួលបានព័ត៌មានព្រមានជាមុនពីគ្រោះមហន្តរាយ។ | ១៥-សិក្សាប៉ាន់ប្រមាណពីតម្រូវការវគ្គបណ្តុះបណ្តាល<br>១៦-រៀបចំច្រងក្រងឯកសារ និងវិធីសាស្ត្រសមស្របសម្រាប់បណ្តុះបណ្តាលឱ្យមានសុវត្ថិភាព<br>១៧-បណ្តុះបណ្តាលគ្រូ និងសិស្សសាលា ព្រមទាំងផ្តល់នូវឧបករណ៍ពាក់ព័ន្ធ<br>១៨-រៀបចំការបង្ហាត់ហែលទឹក និងបង្ហាត់កិច្ចសង្គ្រោះដោយសហការជាមួយកន្លែង ឬក្លឹបហែលទឹកក្នុងស្រុក ឬកន្លែងដទៃទៀត<br>១៩-បណ្តុះបណ្តាលសមាជិកសហគមន៍ឱ្យឆ្លើយតបទៅនឹងព័ត៌មានព្រមានជាមុនអំពីទឹកជំនន់ និងខ្យល់ព្យុះនានា។ |

| **<u>យុទ្ធសាស្ត្រទី៣៖</u> លើកកម្ពស់ការគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យពីការលង់ទឹកជាមូលដ្ឋានសម្រាប់ធ្វើផែនការ និងចាត់វិធានការនានាឱ្យបានសម ស្រប តាមតម្រូវការជាក់ស្តែង នៃភាពងាយរងគ្រោះដោយការលង់ទឹក** | | |
|---|---|---|
| **កម្មវិធីការងារអាទិភាពទី៣.១ ៖** សិក្សាពីចរិកលក្ខណៈ នៃហានិភ័យ ភាពងាយរងគ្រោះ និងកត្តាចម្បងនានា បណ្តាលឱ្យមានការលង់ទឹក និងមានទិន្នន័យជាក់លាក់ជាមូលដ្ឋានធ្វើសកម្មភាព | • ចំនួនការសិក្សា និងរបាយការណ៍សិក្សា វិភាគពីកត្តាចម្បងនានា ដែលបណ្តាលឱ្យមានការលង់ទឹក ហានិភ័យ និងផលវិបាកទាំងបន្ទាន់ និងរយៈពេលវែង<br>• ទិន្នន័យជាក់លាក់បែបគុណភាព និងបរិមាណស្តីពី ការលង់ទឹក<br>• អនុសាសន៍នានា ដើម្បីដោះស្រាយការលង់ទឹករយៈពេលខ្លី មធ្យម និងវែង<br>• ចំនួនរបាយការណ៍បានបោះពុម្ព និងផ្សព្វផ្សាយ។ | ២០-វិភាគលើទិន្នន័យ និងរបាយការណ៍នានា ដែលមានស្រាប់ពីមូលហេតុចម្បងៗ នៃភាពងាយរងគ្រោះដោយការលង់ទឹក<br>២១-រៀបចំក្រុមការងារប្រមូល និងបញ្ចូលទិន្នន័យនៅថ្នាក់ជាតិ និងក្រោមជាតិ ស្តីពីការលង់ទឹក<br>២២-បង្កើតឱ្យមានការសិក្សាវាយតម្លៃជាក់លាក់ និងទូលំទូលាយពីប្រភេទហានិភ័យ និងភាពងាយរងគ្រោះ<br>២៣-បោះពុម្ព និងធ្វើការផ្សព្វផ្សាយរបាយការណ៍ឱ្យបានទៀងទាត់ និងជាបន្តបន្ទាប់។ |
| **កម្មវិធីការងារអាទិភាពទី៣.២ ៖** រៀបចំជាប្រព័ន្ធទិន្នន័យជាក់លាក់ សម្រាប់កត់ត្រាការលង់ទឹក និង កិច្ចការនានា ពីការការពារ និង គ្រប់គ្រងការលង់ទឹក | • របាយការណ៍វិភាគជាមូលដ្ឋាន នៃការរៀបចំប្រព័ន្ធទិន្នន័យស្តីពីការលង់ទឹក(បញ្ចូលជាមួយប្រព័ន្ធ ដែលមានស្រាប់ណាមួយឬ បង្កើតថ្មី?) | ២៤-សិក្សាពិនិត្យមើលរបាយការណ៍ និងឧបករណ៍ ឬវិធីសាស្ត្រកត់ត្រាទិន្នន័យនានា ដែលពាក់ព័ន្ធថាតើមានបញ្ចូលនូវទិន្នន័យជាក់លាក់ពីការលង់ទឹកបានដល់កម្រិតណា<br>២៤-បង្កើត ឬសម្រួលបន្ថែមឱ្យមានប្រព័ន្ធទិន្នន័យកត់ត្រាការលង់ទឹក ដើម្បីដាក់ឱ្យប្រើប្រាស់ព្រមទាំងឱ្យមានយន្តការអនុវត្តជាក់លាក់ |

| | | |
|---|---|---|
| | • មានប្រព័ន្ធសម្រាប់កត់ត្រាទិន្នន័យពីការលង់ទឹកដែលមានមាតិកាទិន្នន័យសំខាន់ៗត្រូវបញ្ចូល<br>• មានយន្តការ និងក្រុមការងារជាក់លាក់សម្រាប់រាយការណ៍ និងកត់ត្រាទិន្នន័យ<br>• ក្រុមការងារបានទទួលការបណ្តុះបណ្តាល<br>• មានសៀវភៅណែនាំ ស្តីពីការប្រើប្រាស់ប្រព័ន្ធទិន្នន័យ | |
| **កម្មវិធីការងារអាទិភាពទី៣.៣៖** ប្រមូលវិភាគទិន្នន័យ និងបោះពុម្ពរបាយការណ៍ការលង់ទឹកឱ្យបានទៀងទាត់ | • ទិន្នន័យ ស្តីពីការលង់ទឹក និងកិច្ចការឬវិធានការនានាត្រូវបានកត់ត្រាចូលយ៉ាងទៀងទាត់<br>• របាយការណ៍ ស្តីពីការលង់ទឹកត្រូវបានបោះពុម្ព និងផ្សព្វផ្សាយយ៉ាងទៀងទាត់<br>• ស្ថាប័នពាក់ព័ន្ធអាចទាញយកទិន្នន័យមកប្រើប្រាស់បាន។ | ២៥-ពិនិត្យតាមដាន និងធ្វើរបាយការណ៍ស្តីពីការអនុវត្តគោលនយោបាយការការពារ និងគ្រប់គ្រងការលង់ទឹក<br>២៦-បណ្តុះបណ្តាលក្រុមការងារឱ្យបានទៀងទាត់ ពីរបៀបបញ្ចូល និងប្រើប្រាស់ប្រព័ន្ធទិន្នន័យ<br>២៧-បោះពុម្ពរបាយការណ៍ និងផ្សព្វផ្សាយឱ្យបានទៀងទាត់។ |

| យុទ្ធសាស្ត្រទី៤៖ ពង្រឹងយន្តការនិងសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តការងារការពារ និងគ្រប់គ្រងការលង់ទឹក | | |
|---|---|---|
| **កម្មវិធីការងារអាទិភាពទី៤.១ ៖** ពង្រឹងភាពជាដៃគូ និង កិច្ចសហប្រតិបត្តិការ | • បណ្តាញក្រុមការងារ និងភាពជាដៃគូសម្រាប់ការការពារ និងគ្រប់គ្រងការលង់ទឹក ត្រូវបានបង្កើតឡើង<br>• កិច្ចប្រជុំក្រុមការងារបណ្តាញ និងភាពជាដៃគូសម្រាប់ការការពារ និងគ្រប់គ្រងការលង់ទឹក។ | ២៨-បង្កើតសម្ព័ន្ធភាពឬបណ្តាញក្រុមការងារ ដើម្បីសហការជាមួយអង្គការជាតិ អន្តរជាតិនានា និងស្ថាប័នពាក់ព័ន្ធនានារួមទាំងវិស័យឯកជន<br>២៩-បើកកិច្ចប្រជុំជាទៀងទាត់របស់សម័ន្ធភាពក្រុមការងារ<br>៣០-បើកកិច្ចប្រជុំជាទៀងទាត់របស់សម័ន្ធភាពក្រុមការងារ<br>៣១-ចូលរួមជាមួយបណ្តាញការងារដែលមានស្រាប់នានាសម្រាប់ធ្វើការតស៊ូមតិឱ្យមានការយកចិត្តទុកដាក់លើការលង់ទឹក<br>៣២-ស្វែងរកការគាំទ្រពីដៃគូពាក់ព័ន្ធ និងសកម្មភាពលើកទឹកចិត្តដល់ការអនុវត្ត។ |
| **កម្មវិធីការងារអាទិភាពទី៤.២ ៖** បណ្តុះបណ្តាលក្រុមគ្រូបង្គោលស្តីពីសុវត្ថិភាពទឹកសម្រាប់ធ្វើការបណ្តុះបណ្តាលបន្ត | • ចំនួនគ្រូបង្គោលបានទទួលការបណ្តុះបណ្តាល និងអាចបង្រៀនបន្តបាន<br>• ចំនួនឯកសារបច្ចេកទេសជាក់លាក់ និងត្រូវតាមបច្ចេកទេសសម្រាប់ធ្វើការបណ្តុះបណ្តាលគ្រូ<br>• ចំនួនវគ្គបណ្តុះបណ្តាលគ្រូបង្គោល។ | ៣៣-សិក្សាប៉ាន់ប្រមាណពីតម្រូវការវគ្គបណ្តុះបណ្តាល<br>៣៤-រៀបចំចងក្រងឯកសារ និងវិធីសាស្ត្រសមស្របសម្រាប់បណ្តុះបណ្តាលឱ្យមានសុវត្ថិភាព<br>៣៥-បើកវគ្គបណ្តុះបណ្តាល<br>៣៦-ការតាមដាន និងវាយតម្លៃវគ្គបណ្តុះបណ្តាល<br>៣៧-រៀបចំទស្សនកិច្ចសិក្សាទៅប្រទេសក្នុងតំបន់ ដើម្បីរៀនសូត្រពីបទពិសោធល្អនានា។ |

| | | |
|---|---|---|
| **កម្មវិធីការងារអាទិភាពទី៤.៣៖** រៀបចំផែនការ ប្រចាំឆ្នាំ និងផែនការសកម្មភាពការងារ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក | • ចំនួនផែនការសកម្មភាពប្រចាំឆ្នាំរបស់ក្រសួង និងមន្ទីរសុខាភិបាល និងស្ថាប័នពាក់ព័ន្ធស្តីពី ការការពារ និងគ្រប់គ្រងការលង់ទឹក<br>• ចំនួនផែនការត្រូវបានគិតគូអនុវត្តន៍ និងវិភាជន៍ថវិកា<br>• ចំនួនផែនការត្រូវបានអនុវត្ត និងវាយតម្លៃ និងចងក្រងជារបាយការណ៍វឌ្ឍនៈភាព។ | ៣៨-ធ្វើការវាយតម្លៃប្រចាំឆ្នាំនៅកន្លែងមានការលង់ទឹកញឹកញាប់ និងសហគមន៍ដែលងាយរងគ្រោះ<br>៣៩-សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើតផែនការសកម្មភាពការពារការលង់ទឹក ដែលសមស្របនឹងសហគមន៍ជាក់លាក់ដោយមានការវិភាជន៍ថវិកាដែលមានស្រាប់<br>៤០-ចងក្រងផែនការអនុវត្តប្រចាំឆ្នាំ និងស្វែងរកការគាំទ្រហិរញ្ញវត្ថុសម្រាប់អនុវត្តពីប្រភពទាំងក្នុង និងក្រៅរដ្ឋាភិបាល<br>៤១-រៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃ រួមទាំងការវាយតម្លៃពាក់កណ្តាលគ្រា និងចុងគ្រា។ |

# ៥. យន្តការអនុវត្តផែនការយុទ្ធសាស្ត្រ

## ៥.១ តួអង្គសំខាន់ៗ និងអភិបាលកិច្ចលើការអនុវត្តន៍

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការការពារ និងគ្រប់គ្រងការលង់ទឹក ដែលជាបញ្ហាសុខភាពសាធារណៈ ក្រសួងសុខាភិបាលតាមរយៈនាយកដ្ឋានការពារសុខភាព ជាតួអង្គរ៉ាប់រងដឹកនាំ និងសម្របសម្រួល ជាមួយនឹងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ តួអង្គសំខាន់ៗ ក្រៅពីក្រសួងសុខាភិបាល មានក្រសួង-ស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល សហគមន៍ រួមទាំងភ្នាក់ងារអង្គការសហប្រជាជាតិនានា។ តួអង្គសំខាន់មួយដែល មិនអាចខ្វះបាន គឺវិស័យឯកជនដែលមានភារកិច្ចក្នុងការដឹកជញ្ជូនខាងផ្លូវទឹក រួមទាំងផ្នែកទេសចរណ៍ ដែលចាំបាច់តម្រូវឱ្យមានការចូលរួមក្នុងការងារនេះ។

ដើម្បីឱ្យការអនុវត្តទទួលបានលទ្ធផលល្អ មានប្រសិទ្ធភាព និងប្រសិទ្ធផល ចាំបាច់ត្រូវមានការវិភាគ តួអង្គប្រតិបត្តិឱ្យបានជាក់លាក់លើស្ថាប័នពាក់ព័ន្ធ នៅពេលរៀបចំផែនការអនុវត្តប្រចាំឆ្នាំនីមួយៗ ប្រយោជន៍ងាយស្រួលដល់ការធ្វើសកម្មភាព និងប្រើប្រាស់ធនធានឱ្យបានសមស្រប។ ការវិភាគតួអង្គនេះ ចាំបាច់ត្រូវផ្តោតលើ ថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ ខណ្ឌ ក្រុង ស្រុក និងសង្កាត់ ឃុំ ស្របតាមទិសដៅ វិមជ្ឈការរបស់រាជរដ្ឋាភិបាល ដើម្បីបង្ខិតសេវាកម្មឱ្យកាន់តែជិតទៅដល់ប្រជាជននៅមូលដ្ឋានក្នុងការស្វែងរកកត្តាជាគន្លឹះ និងដាក់ចេញវិធានការជាក់លាក់ ជំរុញដល់ការផ្តល់សេវាផ្នែកការការពារ និងការគ្រប់គ្រងការលង់ទឹកនេះផងដែរ។

## ៥.២ ការរៀបចំផែនការការងារប្រចាំឆ្នាំ

ឯកសារយុទ្ធសាស្ត្រនេះ គឺជាផែនការកម្រិតយុទ្ធសាស្ត្រ ដែលជាត្រីវិស័យចង្អុលបង្ហាញនូវអាទិភាពចម្បងៗ ដើម្បីដោះស្រាយបញ្ហាការលង់ទឹក ដែលជាបញ្ហាសុខភាពសាធារណៈនៅកម្ពុជា។ ដើម្បីឱ្យមានការអនុវត្តជាក់ស្តែង ចាំបាច់ត្រូវរៀបចំផែនការអនុវត្ត ឬផែនការសកម្មភាពប្រចាំឆ្នាំ ឆមាស ត្រីមាស និងប្រចាំខែ ដោយបញ្ជ្រាបចូលក្នុងផែនការសកម្មភាពរបស់ក្រសួងសុខាភិបាល និងដៃគូសហការនានាផងដែរ។ ផែនការប្រតិបត្តិការសកម្មភាពនេះ គឺជាមូលដ្ឋានអនុវត្តជាក់ស្តែង និងជាមូលដ្ឋានកៀរគរធនធានសម្រាប់គាំទ្រដល់សកម្មភាព ដែលបានដាក់ចេញសម្រាប់អនុវត្ត។ ការរៀបចំផែនការអនុវត្ត ឬផែនការសកម្មភាពនេះ គួរផ្អែកតាមនិន្នាការ និងលទ្ធផលជាក់ស្តែង តាមឆ្នាំនីមួយៗ ដែលបានអនុវត្តន៍កន្លងមក និងមានការចូលរួមភាគីពាក់ព័ន្ធផងដែរ។

## ៥.៣ ការកៀរគរធនធាន ការវិភាជន៍ធនធាន និងហិរញ្ញវត្ថុ

ផែនការយុទ្ធសាស្ត្រនេះ អាចអនុវត្តបានដរាបណាមានការវិភាជន៍ធនធានពីប្រភពនានា។ ការងារកៀរគរធនធាន សម្រាប់អនុវត្តន៍គួរតែជាសកម្មភាពជាក់លាក់មួយត្រូវបានដាក់ចូលក្នុងការរៀបចំផែនការផែនការ អនុវត្តប្រចាំឆ្នាំ ឆមាស ត្រីមាស ដូចបានបញ្ជាក់ជូនខាងលើ។

១-ជាបឋមក្រសួងសុខាភិបាល អាចលើកសំណើឱ្យមានការវិភាជន៍ធនធានតាមរយៈយន្តការវិភាជន៍ថវិកាប្រចាំឆ្នាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដល់ក្រសួងសុខាភិបាល ដោយបញ្ជ្រាបផែនការសកម្មភាពប្រចាំឆ្នាំទៅក្នុងផែនការមេរបស់ក្រសួង ដើម្បីអាចទទួលបានការវិភាជន៍ថវិកា។

២-រូបភាពដូចគ្នានេះដែរ ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តនៅតាមក្រសួង ស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាលដែលបានបញ្ជ្រាបការងារការការពារ និងគ្រប់គ្រងការលង់ទឹក ដើម្បីឱ្យមានការវិភាជន៍ថវិកាតាមក្រសួងជំនាញទាំងនោះ។ នៅថ្នាក់ក្រោមជាតិមានអាជ្ញាធររាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក សង្កាត់ ឃុំ និងមន្ទីរពាក់ព័ន្ធក៏អាចមានសកម្មភាពកៀរគរធនធានបានដូចគ្នានឹងភាគីពាក់ព័ន្ធតាមកម្រិតផ្សេងៗ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៣-លើសពីនេះ ក្រសួងសុខាភិបាល អាចស្វែងរកប្រភពថវិកាពីដៃគូសហប្រតិបត្តិការរបស់ខ្លួនដូចជា ភ្នាក់ងារអង្គការសហប្រជាជាតិនានា និងអង្គការមិនមែនរដ្ឋាភិបាល។ ក្រៅពីនេះ ប្រភពធនធានក៏អាចស្វែងរកបានពីស្ថាប័នធនាគារឯកជននានា ដែលមានគម្រោងកម្មវិធីបែបទំនួលខុសត្រូវសង្គម (Cooperate Social Responsibility-CSR) លើកលែងតែប្រភពបានមកពីក្រុមហ៊ុនថ្នាំជក់ និងក្រុមហ៊ុនគ្រឿងស្រវឹង។

៤-ក្រុមហ៊ុនធានារ៉ាប់រង អាចនឹងចាប់អារម្មណ៍ក្នុងការផ្សព្វផ្សាយកម្មវិធីសុវត្ថិភាពសាធារណៈ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងបណ្តឹងទាមទារសំណងទាក់ទងនឹងឧបទ្ទវហេតុទឹក។

ដើម្បីឱ្យកិច្ចការកៀរគរហិរញ្ញវត្ថុនេះ មានដំណើរការ និងមានរូបភាពគត់មត់ ចាំបាច់ត្រូវមានការរៀបចំជាផែនការ និងក្របខ័ណ្ឌការងារជាក់លាក់មួយ ស្តីពីការកៀរគរ និងវិភាជន៍ធនធានសម្រាប់អនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិនេះ។

# ៦. ការពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍វឌ្ឍនភាព

## ៦.១ ការពិនិត្យតាមដាន និងរបាយការណ៍វឌ្ឍនភាព

ការពិនិត្យតាមដាន និងរបាយការណ៍វឌ្ឍនភាពជាផ្នែកសំខាន់ នៃគណនេយ្យភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ជាការចាំបាច់ត្រូវមានផែនការពិនិត្យ តាមដាន និងវាយតម្លៃដូចខាងក្រោម៖

### ៦.១.១ ការពិនិត្យតាមដាន (Monitoring)

- **ការប្រមូលទិន្នន័យដើមគ្រា (Baseline Assessment)៖** ដូចបានបញ្ជាក់ជូនខាងលើ ឯកសារផែនការនេះ គឺជាឯកសារនៅកម្រិតយុទ្ធសាស្ត្រជាតិ ដោយយោងតាមបរិបទជាក់ស្តែង នៃកង្វះទិន្នន័យសមស្រប និងគត់មត់ ស្តីពីការលង់ទឹកនៅក្នុងប្រទេស ដូច្នេះ ផែនការយុទ្ធសាស្ត្រនេះនៅមិនទាន់មានសូចនាករជាក់លាក់នៅឡើយ ចាំបាច់ត្រូវប្រមូលទិន្នន័យដើមគ្រាជាក់លាក់មួយសម្រាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងដាក់ចេញនូវសូចនាករជាបរិមាណនានាជាក់លាក់រួមទាំងសូចនាករជាគោលដៅ (Target) ដើម្បីជាមូលដ្ឋានសម្រាប់វាស់វែងវឌ្ឍនភាព នៃការងារ។

- **ផែនការពិនិត្យតាមដាន និងវាយតម្លៃ (M&E plan)៖** ផែនការពិនិត្យតាមដាន និងវាយតម្លៃនេះ អាចធ្វើជារួម និងបន្ទាប់មកបំបែកទៅតាមឆ្នាំ ដោយយោងតាមផែនការសកម្មភាពប្រចាំឆ្នាំ។ កិច្ចការនេះ ចាំបាច់ត្រូវសមាហរណកម្មទៅក្នុងដំណើរប្រព័ន្ធសម្រាប់ធ្វើផែនការ និងការពិនិត្យតាមដាន វាយតម្លៃ របស់ក្រសួងសុខាភិបាល ដើម្បីបន្សីការងារទៅក្នុងប្រព័ន្ធ និងផែនការរបស់ក្រសួង។ ការរៀបចំផែនការនេះគឺផ្អែកតាមទិន្នន័យដើមគ្រា ដែលបានដាក់ចេញដូចខាងលើ ជាពិសេស ផែនការពិនិត្យតាមដាន និងវាយតម្លៃនេះ ចាំបាច់ត្រូវផ្តល់និយមន័យដល់សូចនាករនីមួយៗ ឱ្យបានជាក់លាក់ ដើម្បីងាយស្រួលវាស់វែងតាមដំណាក់កាលនីមួយៗ។ ចំពោះក្រសួង ឬស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតក៏ចាំបាច់អនុវត្តន៍ដូចគ្នានេះផងដែរ។

### ៦.១.២ របាយការណ៍វឌ្ឍនភាព

ដើម្បីបង្កើតរបាយការណ៍វឌ្ឍនភាពគ្រប់ជ្រុងជ្រោយ សម្រាប់ផែនការយុទ្ធសាស្ត្រការការពារ និងគ្រប់គ្រងការលង់ទឹក ចាំបាច់ក្នុងការអនុវត្តតាមដំណើរការ ដែលបានកំណត់ជារចនាសម្ព័ន្ធ ស្របតាមផែនការពិនិត្យតាមដាន និងវាយតម្លៃ (M&E)។ របាយការណ៍គួរតែត្រូវបានរៀបចំ ដើម្បីឆ្លុះបញ្ចាំងពីទិសដៅយុទ្ធសាស្ត្រ និងសូចនាករលទ្ធផលសំខាន់ៗ (KPIs) ជានានូវការវាយតម្លៃច្បាស់លាស់ នៃវឌ្ឍនភាព។ របាយការណ៍ត្រូវបង្ហាញពីការរកឃើញសំខាន់ៗ សមិទ្ធិផល បញ្ហាប្រឈម និងអនុសាសន៍អមដោយការណែនាំ ដោយគូសបញ្ជាក់ពីគោលបំណង ពេលវេលា និងការតភ្ជាប់ទៅនឹងយុទ្ធសាស្ត្រទាំងមូល។

ក្របខ័ណ្ឌការពិនិត្យតាមដាន និងវាយតម្លៃ ណែនាំដល់ដំណើរការប្រមូលទិន្នន័យ ដោយធានាថាការធ្វើបច្ចុប្បន្នភាពលើការយល់ដឹងរបស់សហគមន៍ ក្របខ័ណ្ឌគោលនយោបាយ និងភាពជាដៃគូ ត្រូវបានចងក្រងជាឯកសារជាមួយនឹងភស្តុតាងដែលអាចផ្ទៀងផ្ទាត់បាន។ ក្របខ័ណ្ឌនេះ មានសារៈសំខាន់ណាស់ក្នុងការប្រៀបធៀបវឌ្ឍនភាពធៀបនឹងទិន្នន័យដើមគ្រាពីឆ្នាំទី១ ហើយកត់សម្គាល់ថា តើព្រឹត្តិការណ៍សំខាន់ៗ ដូចជាការវាយតម្លៃពាក់កណ្តាលអាណត្តិត្រូវបានបំពេញដែរ ឬទេ។ លើសពីនេះ ការវិភាគបញ្ហាប្រឈម និងមេរៀនពិសោធន៍ជួយកំណត់ដល់ផ្នែកសម្រាប់កែលម្អ និងតម្រូវការការគាំទ្រ។

## ៦.២ ការវាយតម្លៃតាមដំណាក់កាល និងការធ្វើបច្ចុប្បន្នភាពផែនការ

- **ការវាយតម្លៃពាក់កណ្តាលអាណត្តិ៖** ជាការចាំបាច់ត្រូវឱ្យមានការវាយតម្លៃពាក់កណ្តាលអាណត្តិក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រ ព្រោះជាលើកទីមួយដែលនៅកម្ពុជាបានផ្តួចផ្តើមធ្វើផែនការនេះ និងដាក់ឱ្យអនុវត្ត។ ក្នុងន័យនេះ ការវាយតម្លៃពាក់កណ្តាលអាណត្តិមានសារសំខាន់ណាស់ ដើម្បីពិនិត្យមើល រៀនសូត្រ និងកែលម្អឱ្យបានទាន់ពេលវេលាសម្រាប់ការអនុវត្តបន្ត។ ផ្អែកតាមលទ្ធផលវាយតម្លៃពាក់កណ្តាលអាណត្តិនេះ ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធអាចធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្របន្ត និងផែនការប្រចាំឆ្នាំឡើងវិញ។ ការវាយតម្លៃពាក់កណ្តាលអណត្តិនេះគួរអនុវត្តន៍នៅឆ្នាំ២០២៧។

- **ការវាយតម្លៃចុងអាណត្តិ៖** បន្ថែមពីការវាយតម្លៃពាក់កណ្តាលអាណត្តិ ចាំបាច់ត្រូវធ្វើការវាយតម្លៃចុងអាណត្តិនៅឆ្នាំចុងក្រោយ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំដំណាក់កាលថ្មីមួយទៀត នៃផែនការយុទ្ធសាស្ត្រនេះ។ ការវាយតម្លៃចុងអណត្តិនេះ គួរពិចារណាធ្វើឡើងនៅឆ្នាំ២០៣០៕